# ការយល់ដឹងពីធម្មនុញ្ញរបស់អាស៊ាន និងផែនការលំអិតស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

**សេចក្តីផ្តើម**

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) គឺជាអង្គការក្នុងតំបន់មួយដែលមានប្រទេសចំនួន១០ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជា ប្រ៊ុយណេ ដារូសាឡឹម, កម្ពុជា, ឥណ្ឌូណេស៊ី, សាធារណៈរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ, ម៉ាឡេស៊ី, ភូមា, ហ្វីលីពីន, ថៃ, សឹង្ហបូរី, និងវៀតណាម ។ សមាគមនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ១៩៦៧ ក្នុងគោលបំណងបង្កើនល្បឿន នៃការលូតលាស់សេដ្ឋកិច្ច, ការវិវឌ្ឍសង្គមជាតិ, និងការអភិវឌ្ឍវប្បធម៌ និងជម្រុញសន្តិភាព និងស្ថេរភាពនៅក្នុងតំបន់ ។

**តារាងទី ១**

**សមាជិកអាស៊ាន និងកាលបរិច្ឆេទនៃការចូល ជាសមាជិក**

| | |
|---|---|
| ប្រ៊ុយណេ ដារូសាឡឹម | ៨ មករា ១៩៨៤ |
| កម្ពុជា | ៣០ មេសា ១៩៩៩ |
| ឥណ្ឌូណេស៊ី | ៨ សីហា ១៩៦៧ |
| សាធារណៈរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ | ២៣ កក្កដា ១៩៩៧ |
| ម៉ាឡេស៊ី | ៨ សីហា ១៩៦៧ |
| ភូមា | ២៣ កក្កដា ១៩៩៧ |
| ហ្វីលីពីន | ៨ សីហា ១៩៦៧ |
| សឹង្ហបូរី | ៨ សីហា ១៩៦៧ |
| ថៃ | ៨ សីហា ១៩៦៧ |
| វៀតណាម | ២៨ កក្កដា ១៩៩៥ |

រយៈពេលជាង៤០ឆ្នាំ នៃការបង្កើតសមាគមនេះឡើង អាស៊ានបានធ្វើសច្ចាប័នលើសេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍ ជាច្រើនដែលតំណាងឱ្យឧត្តមគតិ និងកិច្ចព្រមព្រៀងរបស់សមាគម ។ ទោះបីជាយ៉ាងនេះក្តី អាស៊ានត្រូវបានរិះគន់យ៉ាងខ្លាំងចំពោះការវិវឌ្ឍយឺតយ៉ាវរបស់ខ្លួន និងចំពោះការបរាជ័យរបស់ខ្លួននៅក្នុងការដោះស្រាយបញ្ហាវិវាទ ដូចជាសិទ្ធិមនុស្សជាដើម ។ វាត្រូវបានគេស្គាល់ថាជា "មធ្យោបាយរបស់អាស៊ាន" ឬ ការបង្កើតឡើងនូវនយោបាយការទូតដោយផ្អែកលើមូលដ្ឋាននៃការមិនជ្រៀតជ្រែក ការប្រឹក្សាពិគ្រោះយោបល់ និងការស្របមតិគ្នាជាទូទៅ ។

ទោះបីជាមានការរិះគន់មួយផ្នែកក្តី ប៉ុន្តែការងារសំខាន់ជាងនេះទៅទៀតនោះគឺធ្វើឱ្យសមាគមអាស៊ានកាន់តែមានថាមពល គឺសមាគមបានដាក់ចេញនូវគម្រោងប្រកបដោយមហិច្ឆតាជាច្រើនទៀតនៅក្នុងអំឡុងពេល១០ឆ្នាំ ចុងក្រោយនេះ ។

នៅខែធ្នូ ឆ្នាំ១៩៩៧ ទស្សនវិស័យរបស់អាស៊ាន សម្រាប់ឆ្នាំ២០២០ ត្រូវបានអនុម័តឡើងដោយកំណត់គោលដៅយុទ្ធសាស្ត្រសម្រាប់សមាគម ហើយនិងអំពាវនាវ ឱ្យមានការសហការរវាងសមាជិកឆ្ពោះទៅរកការបង្កើត "សហគមន៍សង្គមជាតិដែលពោរពេញដោយការយកចិត្តទុកដាក់" ។ ការងារនេះបានត្រួសត្រាយផ្លូវសម្រាប់ផែនការសកម្មភាពជាបន្តបន្ទាប់ ដើម្បីចាប់ផ្តើមធ្វើការឆ្ពោះទៅរកទស្សនវិស័យដែលបានកំណត់នៅក្នុងទស្សនវិស័យរបស់អាស៊ានសម្រាប់ឆ្នាំ២០២០ ។ ផែនការសកម្មភាពទាំងនេះ បានកំណត់នូវគោលនយោបាយជាក់លាក់ និងគម្រោងដែលសមាជិកអាស៊ាននឹងអនុវត្ត ដើម្បីកំណត់គោលដៅនៃកិច្ចសហប្រតិបត្តិការ និងសហគមន៍ ។ ផែនការសកម្មភាពនេះ មានរយៈពេល៦ឆ្នាំ ហើយត្រូវបានត្រួតពិនិត្យរៀងរាល់៣ឆ្នាំម្តង ។ ផែនការដំបូងនៃផែនការសកម្មភាពនោះ គឺផែនការសកម្មភាពហាណូយដែលបានអនុវត្តចាប់ពី ឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤ ។ ផែនការបច្ចុប្បន្ន គឺកម្មវិធីសកម្មភាពវៀងច័ន្ទ (VAP) ដែលអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០១០ ។

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលលើកទី៩ នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ីកាលពីខែតុលា ឆ្នាំ២០០៣ ថ្នាក់ដឹកនាំរបស់អាស៊ានបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នៃសន្ធិសញ្ញា II របស់អាស៊ាន (នៃសន្ធិសញ្ញា II កោះបាលី) ។ នៅក្នុងកិច្ចព្រមព្រៀងនេះ ថ្នាក់ដឹកនាំបានបញ្ជាក់នូវកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតសហគមន៍អាស៊ាន និងកំណត់កិច្ចសហប្រតិបត្តិការសន្តិសុខ និងនយោបាយ, កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការវប្បធម៌សង្គមដែលជាចំណុចស្នូលទាំងបីរបស់អាស៊ាន ។ កិច្ចព្រមព្រៀងនោះ បានបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សន្តិសុខរបស់អាស៊ាន (ASC) និងសហគមន៍វប្បធម៌សង្គមរបស់អាស៊ាន (ASCC) ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលលើកទី១០ នៅទីក្រុងសាំងហ្គាពួរ ថ្នាក់ដឹកនាំរបស់អាស៊ានបានចុះហត្ថលេខាលើធម្មនុញ្ញរបស់ អាស៊ាន និងផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ។ ការចុះហត្ថលេខាលើឯកសារទាំងពីរ គឺជាសញ្ញានៃការរៀបចំជាផ្លូវការថែមទៀតសម្រាប់សមាគមនេះ ហើយដែលគេហៅថាជាច្បាប់មូលដ្ឋានរបស់អាស៊ាន ។

ធម្មនុញ្ញរបស់អាស៊ានបានក្លាយទៅជាអង្គការប្រចាំតំបន់ដែលដូចជារដ្ឋធម្មនុញ្ញសម្រាប់ប្រទេសដែរ ។ វាតំណាងឱ្យគោលការណ៍ និងគោលដៅមូលដ្ឋានរបស់អង្គការ ហើយបានកំណត់រចនាសម្ព័ន្ធ និងទ្រង់ទ្រាយនៃសមាជិកភាព និងអភិបាលកិច្ចរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ផែនការសេដ្ឋកិច្ចរបស់សហមន៍អាស៊ាន (AEC) ហាក់ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងរបស់ប្រទេសដែលដាក់ចេញនូវគោលការណ៍ និងគម្រោងដែលនឹងត្រូវបានអនុវត្តនៅក្នុងរយៈពេលដែលកំណត់នៅក្នុងអាស៊ាន ផែនការសហគមន៍សដ្ឋកិច្ចអាស៊ាន (AEC) គឺជាផែនការមួយក្នុងចំណោមផែនការទាំងបីដែលនឹងត្រូវប្រើដើម្បីប្រតិបត្តិក្នុងសហគមន៍អាស៊ាន ។ ផែនការពីរ ផ្សេងទៀត គឺសហគមន៍សន្តិសុខនយោបាយ និងផែនការសហគមន៍វប្បធម៌សង្គមដែលនៅកំពុងស្ថិតក្នុងដំណើរការបង្កើតជារូបមន្តនៅឡើយ ។

## តើអ្វីទៅជាធម្មនុញ្ញរបស់អាស៊ាន ?

ធម្មនុញ្ញរបស់អាស៊ានគឺជាកិច្ចព្រមព្រៀង ដើម្បីបង្កើតក្របខ័ណ្ឌច្បាប់ និងរដ្ឋធម្មនុញ្ញសម្រាប់អាស៊ាន ។ វាមានបីជំពូកដែលរួមមាន៥៥មាត្រា និង៤ឧបសម្ព័ន្ធ ។ រចនាសម្ព័ន្ធ និងបទបញ្ញត្តិសំខាន់នៃធម្មនុញ្ញ គឺបានសង្ខេបនៅក្នុងតារាង២ ។ នៅខណៈពេលដែលវាត្រូវបានចុះហត្ថលេខាដោយថ្នាក់ដឹកនាំរបស់អាស៊ាន ធម្មនុញ្ញនេះត្រូវបានធ្វើសច្ចាប័នដោយប្រទេសជាសមាជិកនីមួយៗ ដោយយោងទៅលើដំណើរការនៃការធ្វើសច្ចាប័ន និងច្បាប់របស់ប្រទេសនីមួយៗ ។

ធម្មនុញ្ញបានកំណត់នូវឥស្សរជនស្របច្បាប់សម្រាប់អាស៊ាន។ ធម្មនុញ្ញបានរៀបរយកិច្ចព្រមព្រៀង និងសេចក្ដីថ្លែងការណ៍កាលពីអតីតកាលជាច្រើនរបស់អាស៊ាន, បញ្ជាក់នូវគោលនយោបាយរយៈពេលវែងរបស់សហគមន៍ កិច្ចសហត្រិបត្តការ ការប្រឹក្សាពិគ្រោះយោបល់ និងការស្របមតិគ្នាជាទូទៅ និងរាប់បញ្ចូលទាំងគោលដៅជាក់លាក់របស់សហគមន៍អាស៊ានបូកបីដែលបានកំណត់កាលពីដំបូង។ វាបានកំណត់ការបង្កើតទំនាក់ទំនងខាងក្រៅរបស់សហគមន៍នោះ ហើយនិងរបៀបដែលវាភ្ជាប់ទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត។

មួយផ្នែកធំនៃធម្មនុញ្ញគឺ ដើម្បីបញ្ជាក់នូវការរៀបចំនូវប្រតិបត្តិការណ៍ផ្ទាល់របស់អាស៊ាន ការកំណត់គោលដៅ និងគោលនយោបាយ និងទំនាក់ទំនងរវាងសមាជិករបស់ខ្លួន។ វាបញ្ជាក់នូវបញ្ហានៃសមាជិកភាព និងរៀបចំតួនាទី និងទំនួលខុសត្រូវរបស់អង្គការផ្សេងៗរបស់អាស៊ាន។ វាបានបង្កើតនូវការិយាល័យថ្មីមួយរបស់អាស៊ានដែលមាន ដូចខាងក្រោម :

- ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានដែលមានរដ្ឋមន្ត្រីក្រសួងការបរទេសរបស់អាស៊ានដោយមានកិច្ចប្រជុំពីរដង ក្នុងមួយឆ្នាំ
- ក្រុមប្រឹក្សាសហគមន៍អាស៊ាន : ក្រុមប្រឹក្សាសន្តិសុខនយោបាយអាស៊ាន, ក្រុមប្រឹក្សាសេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាវប្បធម៌សង្គមអាស៊ាន
- អ្នកតំណាងគណៈកម្មាធិការអចិន្ត្រៃយ៍ប្រចាំអាស៊ានដែលមានបេក្ខជនតែងតាំងជាសមាជិកនៅក្នុងជួរឯកអគ្គរដ្ឋទូតដែលមានមូលដ្ឋាននៅក្នុងលេខាធិការដ្ឋានរបស់អាស៊ាននៅក្នុងទីក្រុងហ្សាកាតា ហើយ
- ស្ថាប័នសិទ្ធិមនុស្សរបស់អាស៊ាន ផ្នែកដែលពាក់ព័ន្ធដែលត្រូវកំណត់ដោយកិច្ចប្រជុំរបស់រដ្ឋមន្ត្រីការបរទេសរបស់អាស៊ាន

ការផ្លាស់ប្ដូរក៏ត្រូវបានធ្វើឡើងចំពោះស្ថាប័នមួយចំនួនរបស់អាស៊ានដូចជា :

- ការប្រារព្ធកិច្ចប្រជុំកំពូលពីរដងក្នុងមួយឆ្នាំរបស់អាស៊ានដូរទៅប្រារព្ធតែម្ដងក្នុងមួយឆ្នាំវិញ
- វានឹងមានបេក្ខជនប្រធានតែម្នាក់គត់សម្រាប់ស្ថាប័នជាន់ខ្ពស់របស់អាស៊ាន មានន័យថា ប្រទេសដែលធ្វើជាប្រធានអង្គប្រជុំរបស់អាស៊ានសម្រាប់ឆ្នាំណាមួយ នឹងកាន់តំណែងប្រធានរបស់ស្ថាប័នផ្លូវការភាគច្រើនរបស់អាស៊ាន ហើយ
- ការកំណត់ឡើងវិញ និងការពង្រឹងតួនាទីរបស់អគ្គលេខាធិការ និងលេខាធិការដ្ឋានរបស់អាស៊ាន។

**តារាង ២**

**តារាងណែនាំទៅកាន់ធម្មនុញ្ញរបស់អាស៊ាន**

| ***ធម្មនុញ្ញ*** | ***ចំណងជើង*** | ***បទបញ្ញត្តិសំខាន់ៗ*** |
|---|---|---|
| | បុព្វកថា | បុព្វកថាគឺជាសេចក្ដីថ្លែងដំបូងដែលពន្យល់មូលហេតុចំពោះការអនុម័តធម្មនុញ្ញ និងគោលបំណងសំខាន់ៗដែលនឹងមាននៅក្នុងនោះ។ ចំណុចសំខាន់នៅក្នុងធម្មនុញ្ញគឺជាសេចក្ដីសន្និដ្ឋាន "អំពីការរឹតបន្ដឹង និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន"។ |
| I | គោលបំណង និងគោលការណ៍ | មានគោលបំណងចំនួន១៥ របស់អាស៊ាន ដោយរួមទាំងការបង្កើនទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ និងការផ្សព្វផ្សាយអត្តសញ្ញាណអាស៊ាន។ ធម្មនុញ្ញនេះមានគោលការណ៍ចំនួន ១៤ ដោយវាមាននៅក្នុងសេចក្ដីថ្លែងការណ៍ និងកិច្ចព្រមព្រៀង។ |

| | | |
|---|---|---|
| **II** | ឥស្សរជនស្របច្បាប់ | ធម្មនុញ្ញបានផ្តល់អំណាចទៅឱ្យឥស្សរជនស្របច្បាប់ប្រចាំនៅក្នុងអាស៊ាន |
| **III** | សមាជិកភាព | ធម្មនុញ្ញនេះបានកំណត់សមាជិកភាពរបស់អាស៊ាន សិទ្ធិ និងកាតព្វរបស់សមាជិក និងរបៀបនៃការទទួលសមាជិកថ្មី។ |
| **IV** | អង្គការ | ជំពូកទី IV បានកំណត់ស្ថាប័នផ្លូវការផ្សេងៗគ្នារបស់អាស៊ាន និងកំណត់រចនាសម្ព័ន្ធ និងតួនាទីរបស់ស្ថាប័នទាំងនោះ ស្ថាប័នថ្មីៗត្រូវបានកំណត់អាណត្តិទៅតាមក្រុមប្រឹក្សាសម្របសម្រួលរបស់អាស៊ាន ក្រុមប្រឹក្សាសហគមន៍របស់អាស៊ាន និងអ្នកតំណាងគណៈកម្មាធិការអចិន្ត្រៃយ៍ប្រចាំនៅអាស៊ាន និងស្ថាប័នសិទ្ធិមនុស្សរបស់អាស៊ាន។ |
| **V** | អង្គភាពពាក់ព័ន្ធនឹងអាស៊ាន | ជំពូកនេះបានកំណត់នូអង្គភាពដែលមានការពាក់ព័ន្ធនឹងអង្គការ និងកំណត់អណត្តិសម្រាប់អ្នកតំណាងគណៈកម្មធិការអចិន្ត្រៃដើម្បីផ្តល់បញ្ញត្តិទៅលើក្រមនីតិវិធី និងលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធជាមួយវា។ |
| **VI** | អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិ | ជំពូកនេះបានផ្តល់អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិទៅឱ្យអាស៊ានក្នុងករណីចាំបាច់សម្រាប់ការអនុវត្តតួនាទីរបស់ខ្លួន។ អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិគឺមាននៅក្នុងកិច្ចព្រមព្រៀងដាច់ដោយឡែកពីគ្នារបស់អាស៊ាន។ |
| **VII** | ការធ្វើសេចក្តីសម្រេចចិត្ត | ជំពូកនេះបានបញ្ជាក់បន្ថែមទៀតនូវការប្រឹក្សា និងការយល់ស្របគ្នាដែលជាគំរូដំបូងនៅក្នុងការធ្វើការសម្រេចចិត្ត។ |
| **VIII** | ការដោះស្រាយវិវាទ | គោលការណ៍ទូទៅបានអំពាវនាវឱ្យមានការពិគ្រោះយោបល់គ្នា និងការចរចានៅក្នុងការដោះស្រាយវិវាទ។ វិវាទដែលមិនអាចដោះស្រាយបានត្រូវដាក់ទៅកាន់កិច្ចប្រជុំកំពូលរបស់អាស៊ានសម្រាប់ការធ្វើការសម្រេចចិត្ត។ |
| **IX** | ថវិកា និងហិរញ្ញវត្ថុ | ថវិកាប្រតិបត្តិការរបស់អាស៊ានផ្គត់ផ្គង់ដោយការបរិច្ចាគស្មើៗគ្នាប្រចាំឆ្នាំរបស់សមាជិក។ |
| **X** | រដ្ឋបាល និងនីតិវិធី | ដំណែងប្រធានអង្គប្រជុំរបស់អាស៊ានគឺមានការផ្លាស់ប្តូរវេនវៀងរាល់ឆ្នាំ។ ភាសាអង់គ្លេសត្រូវបានអនុម័តធ្វើជាភាសាសម្រាប់ការងាររបស់អស៊ាន។ |
| **XI** | អត្តសញ្ញាណ និងនិមិត្តសញ្ញា | "ទស្សនវិស័យមួយ អត្តសញ្ញាណមួយសហគមន៍មួយ" គឺជាបាវចនារបស់អាស៊ាន។ |
| **XII** | ទំនាក់ទំនងខាងក្រៅ | អ្នកសម្របសម្រួលកិច្ចពិគ្រោះយោបល់ត្រូវបានកំណត់អណត្តិក្នុងការធ្វើជាតំណាងរបស់អាស៊ាន និងកិច្ចប្រជុំរួមគ្នាជាមួយនឹងដៃគូសន្ទនា។ |
| **XIII** | បទបញ្ញត្តិទូទៅចុងក្រោយ | ការធ្វើសច្ចាប័នលើធម្មនុញ្ញរបស់អាស៊ានគឺត្រូវស្របទៅតាមនីតិវិធីផ្ទៃក្នុងរបស់សមជិក។ ការពិនិត្យធម្មនុញ្ញឡើងវិញអាចនឹងត្រូវធ្វើឡើង៥ឆ្នាំបន្ទាប់ពីវាបានចូលជាធរមាន។ |
| **ឧបសម្ព័ន្ធ ១** | ស្ថាប័នក្រសួងតាមផ្នែករបស់អាស៊ាន | ឧបសម្ព័ន្ធនេះ មានតារាងរាយនាមស្ថាប័នតាមផ្នែកដែលស្ថិតនៅក្រោមសហគមន៍អាស៊ានបួកបី (សន្តិសុខនយោបាយ, សេដ្ឋកិច្ច និងវប្បធម៌សង្គម)។ |
| **ឧបសម្ព័ន្ធ ២** | អង្គភាពពាក់ព័ន្ធនឹងអាស៊ាន | ឧបសម្ព័ន្ធនេះ មានតារាងរាយនាមស្ថាប័នដែលមានការពាក់ព័ន្ធនឹងអាស៊ាន តាមក្រុមផ្សេងៗ : សមាជិកសភា, អង្គការពាណិជ្ជកម្ម, ក្រុមពិគ្រោះយោបល និងស្ថាប័នសិក្សា |

| | | |
|---|---|---|
| | | អង្គការសង្គមស៊ីវិលដែលបានទទួលអំណាច និងភាគីពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងអាស៊ាន ។ |
| **ឧបសម្ព័ន្ធ ៣** | ទង់ជាតិរបស់អាស៊ាន | ឧបសម្ព័ន្ធនេះ ផ្ដល់អត្ថន័យនៃទង់ជាតិអាស៊ាន និងបញ្ជាក់នូវទំហំ និងការរៀបចំរបស់ខ្លួន ។ |
| **ឧបសម្ព័ន្ធ ៤** | បដិរូបរបស់អាស៊ាន | ឧបសម្ព័ន្ធនេះ ផ្ដល់អត្ថន័យនៃបដិរូបរបស់អាស៊ាន និងបញ្ជាក់នូវទំហំ និងការរៀបចំរបស់ខ្លួន ។ |

**តើអ្វីទៅជាការឆ្លើយតបទៅនឹងធម្មនុញ្ញរបស់អាស៊ាន ?**

ធម្មនុញ្ញរបស់អាស៊ានត្រូវបានធ្វើឡើងដើម្បីបំពេញនូវប្រតិកម្មរួមគ្នាពីផ្នែកផ្សេងៗគ្នាជាច្រើន ។ រដ្ឋាភិបាលនៅក្នុង និងក្រៅអាស៊ានបានចាត់ទុកការធ្វើសច្ចាប័នទៅលើធម្មនុញ្ញរបស់អាស៊ានថាជាជំហានដ៏សំខាន់ឆ្ពោះទៅកាន់ការផ្ដល់ការអនុវត្តច្បាប់ចំពោះកិច្ចព្រមព្រៀង និងសេចក្ដីថ្លែងការណ៍របស់អាស៊ាន ។ ធម្មនុញ្ញនេះក៏ត្រូវបានគេមើលឃើញផងដែរថាជាការបន្ថែមភាពផ្លូវការទៅឱ្យអាស៊ាន ដោយការបង្កើតច្បាប់ និងការផ្ដល់សញ្ញានៅក្នុងការតាំងចិត្តក្នុងការអនុវត្តនូវកិច្ចព្រមព្រៀងរបស់អាស៊ានដោយយោងទៅលើច្បាប់ផ្លូវការនេះ ។

ទោះបីជាយ៉ាងនេះក្ដី អង្គការសង្គមស៊ីវិលជាច្រើននៅមានការមិនពេញចិត្តព្រោះថា ធម្មនុញ្ញរបស់អាស៊ាន មានការខ្វះចន្លោះលើចំណុចពិស្ដារសំខាន់ៗនៅក្នុងកន្លែងជាច្រើន ហើយថែមទាំងខកខានមិនបានបង្កើតកន្លែងបន្ថែមទៀត សម្រាប់ការចូលរួមរបស់ប្រជាជន ។ ជាអាទិ៍ វាមិនមានយន្តការច្បាស់លាស់សម្រាប់ការដោះស្រាយវិវាទ គណនេយ្យភាព និងការកែប្រែ ។ សេចក្ដីពិស្ដារភាគច្រើនសម្រាប់យន្តការទាំងនេះ គឺទុកឱ្យស្ថាប័នក្រសួងជាអ្នកកំណត់ ។ នៅពេលដែលធម្មនុញ្ញនិយាយអំពីអាស៊ាន ដែលមានការចូលរួមរបស់ប្រជាជន វាមិនមានយន្តការច្បាស់លាស់សម្រាប់តម្លាភាព និងការចូលរួមនោះទេ ។ គេមិននិយាយអំពីថាតើប្រតិបត្តិការណ៍របស់អាស៊ានអាចនឹងស្ថិតនៅក្រោមការពិនិត្យពិច័យវិធីដែលប្រជាជនមានការចាប់អារម្មណ៍អាចចូលរួមនៅក្នុងដំណើរការជាផ្លូវការរបស់អាស៊ាន និងវិធីដែលអាស៊ាននឹងអាចធ្វើឱ្យគេទទួលព័ត៌មានបាន ។

ធម្មនុញ្ញបានផ្ដល់នូវបទបញ្ញត្តិសម្រាប់រដ្ឋាភិបាលកណ្ដាលរបស់អាស៊ាន ប៉ុន្តែមិនបានបញ្ចូល ឬ បញ្ជាក់នូវបទបញ្ញត្តិសម្រាប់ប្រជាជន ជាពិសេស កសិករ ពលករធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ និងស្ត្រីនោះទេ ។

ធម្មនុញ្ញមានបំណងយ៉ាងខ្លាំងចំពោះការបង្កើនសេដ្ឋកិច្ចទីផ្សារ ។ គោលដៅទីផ្សារ និងមូលដ្ឋានផលិកម្មតែមួយដែលហាក់ដូច ជាផ្ដោតទៅលើតែទីផ្សារសេរីហាក់មិនបានផ្ដោតការយកចិត្តដាក់ខ្លាំងលើការធ្វើអន្តរាគមន៍សេដ្ឋកិច្ចដែលអាចធ្វើទៅបានផ្សេងទៀត ។ បញ្ហានេះបានក្លាយជាកង្វល់នៅពេលដែលរួមគ្នាជាមួយផែនការរបស់ AEC ដែលត្រូវបានលើកមកពិភាក្សានៅខាងក្រោមនេះ ។

បទបញ្ញត្តិដែលបានទទួលការស្វាគមច្រើនជាងគេនៅក្នុងធម្មនុញ្ញរបស់អាស៊ាន គឺការបញ្ចូលសិទ្ធិមនុស្ស និងការបញ្ជាក់ពីគោលការណ៍នៅក្នុងបុព្វកថា និងការបង្កើតស្ថាប័នសិទ្ធិមនុស្ស ។ ប៉ុន្តែស្ថាប័នសិទ្ធិមនុស្សដែលជាកម្មវត្ថុនៅក្នុងការតស៊ូមតិរបស់សង្គមស៊ីវិលអស់រយៈពេលស្ទើរតែមួយទសវត្សរ៍កន្លះទៅហើយនោះ មិនទាន់ត្រូវបានពន្យល់បកស្រាយនៅឡើយទេ ។ ល័ក្ខខ័ណ្ឌយោងសម្រាប់ស្ថាប័នសិទ្ធិមនុស្សនឹងនៅតែត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងការបរទេស ។

ជាចុងក្រោយ ដំណើរការបង្កើតធម្មនុញ្ញគឺមានការប្រឹក្សាដែលមានភាពមិនគ្រប់គ្រាន់ ។ គ្មានពង្រាងត្រូវបានតាក់តែងឡើង ដើម្បីឱ្យប្រជាជនអាចយកវាមកពិភាក្សានៅមុនពេលវាត្រូវបានធ្វើការអនុម័តជាចុងក្រោយនោះទេ ។ កង្វល់ដែលកំពុងត្រូវបានលើកឡើងនៅពេលបច្ចុប្បន្ននេះគឺថា ធម្មនុញ្ញនឹងត្រូវបានធ្វើសច្ចាប័នដោយគ្មានការយល់ដឹងរបស់ប្រជាជនអំពីការ

ជំពាក់ជំពិនរបស់វាទាំងមូល ។ ស្រដៀងគ្នានេះដែរ យន្តការជាច្រើនដែលបានកំនត់អណត្តិ ដោយធម្មនុញ្ញចាំបាច់ត្រូវមានការពន្យល់បកស្រាយ និងគាំទ្រដោយផែនការដោយឡែកពីគ្នា ឬ ល័ក្ខខ័ណ្ឌយោង ។ វាស្រដៀងគ្នាទៅនឹងនីតិកម្មដែលអាចធ្វើទៅបានសម្រាប់បទបញ្ញត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសមួយ ។ ការធ្វើពង្រាងអនុវត្តច្បាប់ និងនីតិកម្មសម្រាប់ច្បាប់ដែលត្រូវបានប្រើ ។ ការធ្វើពង្រាងផែនការ និងល័ក្ខខ័ណ្ឌយោងទាំងនេះ- ជាពិសេស ថាតើវានឹងមានប្រជាធិបតេយ្យ និងយកមកប្រើបានប៉ុណ្ណាហើយនិងតើវាបានទទួលការប្រឹក្សា និងពិភាក្សាប៉ុណ្ណា- គឺមានសារៈសំខាន់ដូចគំនិតដែលបង្ហាញនៅក្នុងធម្មនុញ្ញនោះឯង ។

**តើសហគមន៏សេដ្ឋកិច្ចអាស៊ាន (AEC) ជាអ្វី?**

AEC គឺជាស្នូលមួយក្នុងចំណោមស្នូលនៅក្នុងក្តីសុបិន្តរបស់សហគមន៏អាស៊ានដែលបានដាក់នៅកិច្ចព្រមព្រៀងII នៅកោះបាលី ។ អាស៊ានសង្ឃឹមថានឹងបង្កើតទីផ្សារ និងមូលដ្ឋានផលិកម្មតែមួយមិនឱ្យហួសពីឆ្នាំ២០១៥ឡើយ ។ នេះមានន័យថាមិនហួសពីឆ្នាំ២០១៥ ទេ ការដឹកជញ្ជូនទំនិញ, សេវាកម្ម, វិនិយោគទុន និងការងារជំនាញនៅក្នុងអាស៊ាននឹងបើកចំហទាំងស្រុង និងសេរី ហើយការចរាចរដើមទុននឹងមានការរឹតបន្តឹងកាន់កាន់តែតិច ។ វានឹងនៅតែមានភាពបត់បែន និងករណីលើកលែង និងការរឹតបន្តឹង ខ្លះៗ (ជាពិសេស ការចរាចរប្រាក់ និងដើមទុន) ចំពោះសេរីភាវូបណីយកម្មនេះ និងសមាជិកដែលមិនទាន់បានត្រៀមខ្លួនរួចរាល់ក្នុងការធ្វើសេរីភាវូបណីយកម្មលើផ្នែកសេវាកម្មរបស់ពួកគេអាចនឹងជ្រើសរើសយកការពន្យាក្នុងការបើកចំហផ្នែកនោះ (រូបមន្តដក របស់អាស៊ាន) ។ ទោះបីជាយ៉ាងណា គោលដៅយុទ្ធសាស្ត្រ និងការខិតខំប្រឹងប្រែងគឺដើម្បីលុបបំបាត់ការរឹតបន្តឹង និងករណីលើកលែងទាំងអស់នេះ និងដើម្បីឱ្យសមាជិកទាំងអស់មានការខិតខំប្រឹងប្រែងដូចៗគ្នា ។

ទីផ្សារ និងមូលដ្ឋានផលិកម្មតែមួយគឺមានន័យថាជា ការជំនួសពីការមើលការខុសត្រូវតែលើទីផ្សារ និងធនធានដែលនៅក្នុងព្រំដែនរបស់ប្រទេស និងជាប់ពាក់ព័ន្ធតួអង្គសេដ្ឋកិច្ចរបស់ប្រទេសប៉ុណ្ណោះទេ តែសមាជិកទាំងអស់ត្រូវមើលការខុសត្រូវក្នុងតំបន់ទាំងមូលតែម្តង ។ នេះមានន័យថា ប្រទេសជាសមាជិកមួយនឹងមើលការខុសត្រូវទំនិញ និងសេវាកម្មដែលមកពីប្រទេសណាមួយនៅក្នុងអាស៊ាន តាមរបៀបដូចគ្នាដែលប្រទេសនោះមើលការខុសត្រូវចំពោះទំនិញរបស់ប្រទេសខ្លួនអ៊ីចឹងប្រទេសនោះនឹងផ្តល់បុព្វសិទ្ធិ និងឱកាសទទួលបានវិនិយោគិនរបស់អាស៊ានស្មើគ្នាដូចដែលប្រទេសនោះផ្តល់ទៅឱ្យវិនិយោគិនប្រទេសរបស់ខ្លួនដែរ ហើយពលករជំនាញ និងពលករអាជីពនឹងអាចប្រកបរបរនៅក្នុងប្រទេសណាមួយនៅក្នុងអាស៊ាន ដោយសេរី ។

ដើម្បីសម្របសម្រួលការធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារ និងមូលដ្ឋានផលិកម្មតែមួយឱ្យកាន់តែមានល្បឿនទៅមុខ AEC បានផ្តោតការយកចិត្ត ជាពិសេសលើវិស័យពីរគឺ : វិស័យដែលធ្វើសមាហរណកម្មជាអាទិភាព និងចំណីអាហារ, កសិកម្ម និងរុក្ខាប្រមាញ់ ។ មានវិស័យ ដែលធ្វើសមាហរណកម្មជាអាទិភាពមានចំនួន ១២ គឺ : ផលិតផលកសិកម្ម, គ្រឿងយន្ត, ឧបករណ៏អេឡិចត្រូនិក, ការនេសាទ, ផលិតផលកៅស៊ូ, វាយនភ័ណ្ឌ និងសំលៀកបំពាក់, ផលិតផលព្រៃឈើ, អាកាសចរណ៏, ការប្រើបច្ចេកវិទ្យាអេឡិចត្រូនិចសម្រាប់អាស៊ាន, ការថែរក្សាសុខភាព, ទេសចរ, ផ្នែកភស្តុភារ ។ ទាំងនេះជាវិស័យដែលសមាជិកអាស៊ានភាគច្រើនមានចំណាប់អារម្មណ៏ហើយជាចំណុចដែលសមាជិកអាស៊ានបានបំពេញជាមួយគ្នាភាគច្រើន ។ គំនិតនោះគឺថា ប្រសិនបើវិស័យទាំងនេះត្រូវបានធ្វើសេរីភាវូបណីយកម្មទាំងស្រុង ផ្នែកទាំងនេះនឹងត្រូវបានធ្វើសមាហរណកម្មសមាជិកអាស៊ាននឹងអភិវឌ្ឍគុណប្រយោជន៏នៅក្នុងតំបន់នៅក្នុងវិស័យទាំងនេះដោយការទាក់ទាញវិនិយោគទុន និងពាណិជ្ជកម្មនៅក្នុងអាស៊ាន (ជាអាទិ៏ ដោយការចុះកិច្ចសន្យាខាងក្រៅជាមួយគ្នា) និងជួយអភិវឌ្ឍផលិតផល "ដែលផលិតនៅក្នុងអាស៊ាន ។

ការផ្តោតជាពិសេសទៅលើចំណីអាហារ កសិកម្ម និង រុក្ខាប្រមាញ់ត្រូវធ្វើយ៉ាងដើម្បីអភិវឌ្ឍវិស័យណាមួយដែលត្រូវបានចាត់ទុកថា មានភាពសមស្របបំផុតសម្រាប់សមាជិកអាស៊ាន។ សម្រាប់ប្រទេសដែលបានធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារតែមួយ ផែនការរបស់ AEC គឺសំឡឹងមើលនូវរបៀបដែលការធ្វើសេរីភាវូបណីយកម្មនៅក្នុងតំបន់នេះនឹងត្រូវបានអនុវត្ត ហើយតើបទដ្ឋានទូទៅនឹងត្រូវបានអភិវឌ្ឍដោយរបៀបណា។ វាមានការពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការ និងការផ្ទេរបច្ចេកវិទ្យាដោយមានការជួយជ្រោមជ្រែងពីសំណាក់អង្គការអន្តរជាតិ/តំបន់ (ដូចជា អង្គការស្បៀងអាហារ និងកសិកម្ម) និងវិស័យឯកជន។ សមាគមន៍ក៏បានអំពាវនាវផងដែរសុំឱ្យមានការភ្ជាប់ទំនាក់ទំនងរវាងផលិតករកសិកម្មតាមរយៈការការផ្សព្វផ្សាយ និងបណ្តាញសហប្រតិបត្តិការណ៍កសិកម្ម។

ក្រៅពីទីផ្សារតែមួយ AEC ស្រមៃទៅដល់តំបន់សេដ្ឋ កិច្ចដែលមានការប្រកួតប្រជែងខ្ពស់, ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមភាព និងការធ្វើសមាហរណកម្មពេញលេញចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ការអភិវឌ្ឍតំបន់ដែលមានការប្រកួតប្រជែងនឹងត្រូវបានធ្វើឡើងដោយការបង្កើតគោលនយោបាយទូទៅមួយចំនួន និងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធដែលមានការចាំបាច់។ ចំពោះប្រការនេះ អាស៊ាននឹងធ្វើឱ្យគោលនយោបាយមានភាពល្អប្រសើរនៅក្នុងការប្រកួតប្រជែងក្នុងការការពារអ្នកប្រើប្រាស់, កម្មសិទ្ធិ បញ្ញា, ការបង់ពន្ធ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូ និក។ សមាគមនឹងស្ថាបនាបណ្តាញដឹកជញ្ជូនរួមគ្នា (ផ្លូវ អាកាស, សមុទ្រ និងដីគោក) អភិវឌ្ឍប្រព័ន្ធ ICT ដែលអាចតភ្ជាប់គ្នា និងប្រើប្រាស់ដោយប្រទេសទាំងអស់នៅក្នុងតំបន់បន្តគម្រោងក្នុងការធ្វើសមាហរណកម្មបណ្តាញអគ្គីសនី និងបណ្តាញទុយោឧស្ម័នជម្រុញអាជីវកម្មរ៉ែឱ្យក្លាយជាវិស័យមួយ និងទាក់ទាញវិស័យឯកជនឱ្យផ្តល់ហិរញ្ញវត្ថុលើគំនិតផ្តួចផ្តើមនេះ។ បញ្ហាសមភាពនឹងត្រូវបានលើកឡើងជាចំបងតាមរយៈការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SMEs) និងលុបបំបាត់គម្លាតនៃការអភិវឌ្ឍរវាងប្រទេសដែលមានជាង/ធំជាង និងប្រទេសដែលក្រជាង និងតូចជាងរបស់អាស៊ាន និងរវាងអាស៊ាន តំបន់ដទៃទៀតតាមរយៈគំនិតផ្តួចផ្តើម សម្រាប់ការធ្វើសមាហរណកម្មអាស៊ាន (IAI)។ IAI គឺជាគម្រោងដែលកំណត់ជំនួយបច្ចេកទេស និងតម្រូវការក្នុងការកសាងសមត្ថភាពរបស់ប្រទេសអាស៊ាន ដើម្បីមានលទ្ធភាពចូលរួមពេញលេញនៅក្នុងសមាហរណកម្មនៅក្នុងតំបន់។ ជាចុងក្រោយ AEC បានរកមើលមធ្យោបាយនានា ដើម្បីធ្វើឱ្យមានភាពប្រសើរនៅក្នុងកិច្ចព្រមព្រៀងអាស៊ានជាមួយនឹងច្បាប់ និងនីតិកម្មពហុភាគីដែលមានស្រាប់ និងបន្តគោលនយោបាយដែលនឹងធ្វើសមាហរណកម្មតំបន់ជាមួយប្រទេសផ្សេងទៀតនៅលើពិភពលោកបន្ថែមទៀត។

**តារាង ៣**

**សមាសធាតុសំខាន់នៃផែនការ AEC**

| ***លក្ខណៈ*** | ***សមាសធាតុសំខាន់*** |
|---|---|
| **ក. ទីផ្សារ និងមូលដ្ឋានពាណិជ្ជកម្មតែមួយ** | |
| *លំហូរទំនិញដោយសេរី* | <u>ការលុបបំបាត់ការបង់ពន្ធគយ</u><br>- រហូតដល់ឆ្នាំ២០១០ សម្រាប់អាស៊ានបូក៦ ហើយរហូតដល់ឆ្នាំ២០១៥ សម្រាប់ CLMV<br>(ដោយមានការបត់បែនសម្រាប់ផលិតផលដែលងាយខូចខាតមួយចំនួនដល់ឆ្នាំ ២០១៨) |

| | |
|---|---|
| | - វិស័យដែលធ្វើសមាហរណកម្មជាអាទិភាព : ដល់ឆ្នាំ២០០៧ សម្រាប់អាស៊ានបូក៦ ហើយឆ្នាំ ២០១២ សម្រាប់ CLMV<br>- តារាងពិសេសសម្រាប់ពន្ធគយ (SL) ដល់ 0-៥% ដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០១០ សម្រាប់ អាស៊ានបូក៦, ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ សម្រាប់វៀតណាម, ថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ សម្រាប់សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមនិតឡាវ និងភូមា, ដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ សម្រាប់កម្ពុជា<br>- ដំណាក់កាលនៃផលិតផលនៅក្នុងតារាងនៃករណីលើកលែងទូទៅ<br><br><u>ការលុបបំបាត់របាំងមិនមែនពន្ធគយ</u><br>ដល់ឆ្នាំ២០១០ សម្រាប់អាស៊ានបូក៥ (អាស៊ានបូក៦ ដកហ្វីលីពីន) ឆ្នាំ២០១២ សម្រាប់ ហ្វីលីពីន ហើយឆ្នាំ២០១៥ ដោយមានការបត់បែនរហូតដល់ឆ្នាំ២០១៨ សម្រាប់ CLMV<br><br>ការចម្លងពាណិជ្ជកម្មតាមរយៈ : ការសម្របសម្រួលពាណិជ្ជកម្ម ការធ្វើសមាហរណកម្មគយច្រកចេញចូលតែមួយរបស់អាស៊ាន ។ |
| *លំហូរសេវាកម្មដោយសេរី* | • លុបបំបាត់រាល់ការរឹតបន្តឹងលើផ្នែកពាណិជ្ជកម្មសេវាកម្មដល់ឆ្នាំ២០១៥<br>• បន្តធ្វើសេរីភាវូបណីយកម្មសេវាកម្មហិរញ្ញវត្ថុដល់ឆ្នាំ២០២០<br>• ការធ្វើសេរីភាវូបណីយកម្មតាមរយៈរូបមន្តអាស៊ានដក X<br>• ការរៀបចំដែលមានការទទួលស្គាល់ទៅវិញទៅមក (MRAs) |
| *លំហូរវិនិយោគទុនដោយសេរី* | វិស័យវិនិយោគទុនអាស៊ាន (AIA) ធ្វើឱ្យបានសម្រេចនៅឆ្នាំ២០១៥ (បើកឧស្សាហកម្មទាំងអស់ការផ្តល់ការមើលការខុសត្រូវដល់វិនិយោគិនជាតិទាំងអស់ដោយមានករណី លើក លែងមួយចំនួន)<br><br>ការបង្កើតកិច្ចព្រមព្រៀងវិនិយោទុនទូលំទូលាយ (ACIA) |
| *លំហូរដើមទុនសេរីជាងមុន* | ពង្រឹងការអភិវឌ្ឍ និងការធ្វើសមាហរណកម្មទីផ្សារដើមទុនអាស៊ាន និងការជម្រុញចលនាទុនឱ្យកាន់តែខ្លាំងឡើង |
| *លំហូរពលកម្មជំនាញដោយសេរី* | ការសម្របសម្រួលចលនា និងការងារអាជីព និងការងារជំនាញដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងសកម្មភាពដែលទាក់ទងនឹងវិនិយោគទុន |
| *វិស័យដែលធ្វើសមាហរណកម្មជាអាទិភាព* | ការធ្វើសមាហរន្តកម្មទូលំទូលាយលើវិស័យអាទិភាពចំនួន១២ ដើម្បីជម្រុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចទាំងអស់ |

| | |
|---|---|
| *ស្បៀងអាហារ កសិកម្ម និងរុក្ខាប្រមាញ់* | ពាណិជ្ជកម្មក្នុង និងក្រៅអាស៊ាន និងការប្រកួតប្រជែងស្បៀងអាហារ ផលិតផល/វត្ថុធាតុកសិកម្ម, និងរុក្ខាប្រមាញ់រយៈពេលយូររបស់អាស៊ានតាមរយៈពាណិជ្ជកម្មសេរីក្នុងវិស័យ កសិកម្ម និងរុក្ខាប្រមាញ់ ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធគ្រប់គ្រងធម្មតា និងច្បាប់នៅក្នុងការ នេសាទ, ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ការផ្តល់វិញ្ញាប័នបត្រព្រៃឈើ និងសន្តិសុខជីវៈចម្រុះ ការដាក់ពាក្យសុំការផ្តល់បទដ្ឋានសម្រាប់សុវត្ថិភាព និងគុណភាព។<br><br>ការសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ និងវិស័យឯកជន។<br><br>ការជម្រុញកិច្ចសហប្រតិបត្តិការកសិកម្មអាស៊ាន |
| **ខ.តំបន់ប្រកួតប្រជែងសេដ្ឋកិច្ច** | |
| | ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយក្នុងការប្រកួតប្រជែង ការការពារអ្នកប្រើប្រាស់ និងកម្មសិទ្ធិបញ្ញា<br><br><u>ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ</u><br>- បណ្តាញដឹកជញ្ជូនគ្រប់គ្រាន់ មានសុវត្ថិភាព និងរួមគ្នាតែមួយ ទីផ្សារអាកាសចរណ៍តែមួយរបស់អាស៊ាន ទីផ្សារដឹកជញ្ជូនតែមួយរបស់អាស៊ាន<br>- ការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក លទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាប្រព័ន្ធ ITC រួមគ្នា ទំនុកចិត្តលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច<br>- កិច្ចសហប្រតិបត្តិការផ្នែកថាមពល រុក្ខជាតិចម្រាញ់ប្រេង បណ្តាញអគ្គិសនី និងទុយោឧស្ម័នទាក់ទងគ្នាទៅវិញទៅមក (ទុយោឧស្ម័នឆ្លងកាត់ពាសពេញអាស៊ាន (TAGP) និងបណ្តាញថាមពលអាស៊ាន (APG))<br>- ពាណិជ្ជកម្ម និងការវិនិយោគទុនលើផ្នែកធានធានរ៉ែ (អាជីវកម្មរ៉ែ)<br>- ការទាក់ទាញការចូលរួមរបស់វិស័យឯកជនឱ្យកាន់តែច្រើន<br><br>ការអភិវឌ្ឍគោលនយោបាយដើម្បីលុបបំបាត់ការយកពន្ធទ្វេ និងដើម្បីលើកស្ទួយពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិកត្រូនិច។ |
| **គ. ការអភិវឌ្ឍសេដ្ឋកិច្ចដែលមានសមភាព** | |
| | ផែនការគោលនយោបាយសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម SME |

| | |
|---|---|
| | (APBSD) ២០០៤-២០១៤<br><br>គំនិតផ្តួចផ្តើមសម្រាប់ការធ្វើសមាហរណកម្មអាស៊ាន (IAI) -ជាយានដើម្បីបង្រួមគម្លាតនៃការអភិវឌ្ឍនៅក្នុងអាស៊ាន និងរវាងអាស៊ាន និងផ្នែកផ្សេងទៀតនៃពិភពលោក |
| **ឃ. ការធ្វើសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចពិភពលោក** | |
| | វិធានភ្ជាប់ទៅកាន់ទំនាក់ទំនងសេដ្ឋកិច្ចខាងក្រៅ (ការយកចិត្តទុកដាក់ចំពោះច្បាប់ និងនីតិកម្មខាងក្រៅ ក្នុងការអភិវឌ្ឍគោលនយោបាយ AEC)<br><br>លើកស្ទួយការចូលរួមនៅក្នុងបណ្តាញផ្គត់ផ្គង់របស់ពិភពលោក |
| **ការអនុវត្ត** | |
| *យន្តការអនុវត្ត* | • តម្លាភាពក្នុងការទទួលព័ត៌មាន<br>• ការធ្វើសច្ចាប័នលើឯកសារច្បាប់ក្នុងរយៈពេល៦ខែ<br>• ការស្របមតិគ្នា<br>• លើកស្ទួយយន្តការដោះស្រាយវិវាទ<br>• រូបមន្ត អាស៊ាន-X<br>• ភាពបត់បែន |
| *ការធ្វើទំនាក់ទំនង* | • ផែនការទំនាក់ទំនង<br>• វេទិកាតំបន់សម្រាប់ការបើកកិច្ចពិភាក្សា<br>• យន្តការថ្នាក់ជាតិសម្រាប់ធ្វើរបាយការណ៍<br>• គេហទំព័ររបស់ AEC |
| *ធនធាន* | • មូលនិធិអភិវឌ្ឍអាស៊ាន (SFF)<br>• ការសិក្សាពីបច្ចេកវិទ្យា<br>• ការបកស្រាយគោលដៅ AEC ទៅជាគោលដៅរបស់ជាតិ<br>• ការចូលរួមរបស់ ADB, WB/IFC, ដៃគូសន្ទនា, វិស័យឯកជន<br>• ពង្រឹងការស្រាវជ្រាវ និងសមត្ថភាពកសាងផែនការរបស់លេខាធិការដ្ឋានអាស៊ាន<br>• ពង្រឹងការស្រាវជ្រាវ និងសមត្ថភាពកសាងផែនការរបស់សមាជិក<br>• ការកសាងសមត្ថភាពសម្រាប់សមាជិកថ្មី |
| *ការពិនិត្យឡើងវិញ* | ការត្រួតពិនិត្យជារយៈពេលរបស់ AEC |

- អាស៊ាន-៦ សំដៅទៅលើ ប្រ៊ុយណេ ដារូសាឡឹម, ឥណ្ឌូណេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីន, សឹង្ហបុរី, និងថៃ
- CLMV សំដៅទៅលើ កម្ពុជា, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ភូមា និងវៀតណាម

**តើ AEC មានន័យដូចម្តេចចំពោះយើងគ្រប់រូប ?**

សហគមន៍សេដ្ឋកិច្ចអាស៊ានគឺជាគោលបំណងដែលប្រកបដោយមហិច្ឆតាដែលជាអកុសលត្រូវបានអភិវឌ្ឍដោយមិនមាន ការប្រឹក្សាប្រកបដោយអត្ថន័យជាមួយនឹងវិស័យសេដ្ឋកិច្ចផ្សេងៗគ្នានៅក្នុងតំបន់។ ជាលទ្ធផលផែនការដែលបានធ្វើពង្រាងឡើង ដើម្បីទ្រទ្រង់សហគមន៍ហាក់ដូចជាមានលក្ខណៈបច្ចេកទេសបន្តិច ហើយមិនអនុញ្ញាតឱ្យតួអង្គសេដ្ឋកិច្ចស្វែងរកតួនាទីសម្រាប់ខ្លួនគេ។ តួអង្គសេដ្ឋកិច្ចសំខាន់ៗ និងពាណិជ្ជកម្មប្រហែលជាស្ថិតនៅក្នុងតំណែងដែលអាចទាញយកគុណប្រយោជន៍ពីគោលនយោបាយ និងគម្រោងដែលបានរៀបរាប់នៅក្នុងផែនការ ប៉ុន្តែវានៅខ្វះគោលនយោបាយ និងគម្រោងជាច្រើនទៀតដែលអាចជួយផលិតករ និងពាណិជ្ជកម្មតូចតាចទទួលយកការធ្វើសមាហរណកម្ម។

គួរកត់សម្គាល់ដែលថា គ្មានការលើកឡើងអំពីកសិករ និងអ្នកនេសាទតូចតាចនៅក្នុងផែនការនេះទេ ហើយការលើកឡើងពីកម្មករ គឺសំដៅតែទៅលើអ្នកមានអាជីព និងកម្មករដែលមានជំនាញខ្ពស់ប៉ុណ្ណោះ។ ការជម្រុញសហប្រតិបត្តិការកសិកម្មត្រូវបានផ្តោតទៅលើការភ្ជាប់ទំនាក់ទំនង និងការភ្ជាប់បណ្តាញ ការស្នើសុំនូវតម្រូវការសម្រាប់ពួកគេក្នុងការប្រមូលផ្តុំគ្នា ហើយក្លាយជាក្រុមធំ។ តើកិច្ចសហប្រតិបត្តិការអាចត្រូវបានអភិវឌ្ឍ ដើម្បីការពារផលិតកម្ម និងការបង្កើនប្រាក់ចំណូលគឺនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ។

AEC ហាក់ដូចជាគិតថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់មានភាពងាយស្រួល និងការធ្វើសេរីភាវូបណីយកម្មដ៏ឆាប់រហ័ស។ វាមិនមានភាពច្បាស់លាស់សោះ ថាតើផលកម្រៃនៃការធ្វើសមាហរណកម្មតំបន់ត្រូវបានរក្សារទុកសម្រាប់តំបន់នោះ។ ជាមួយនឹងគោលដៅនៃការភ្ជាប់ជាមួយនឹងច្បាប់អន្តរជាតិ វាបង្ហាញថា AEC គឺគ្រាន់តែជាវេទិកាមួយ ដើម្បីឱ្យសមាជិកអាស៊ានអាចធ្វើសេរីភាវូបណីយកម្មបានលឿនជាងមុនប៉ុណ្ណោះ។ ផែនការនៅក្នុងការស្វែងរកការទទួលបានទីផ្សារខាងក្រៅរបស់វា (ធ្វើឱ្យអាស៊ានក្លាយជាតំបន់ដែលមានការប្រកួតប្រជែងការធ្វើសេរីភាវូបណីយកម្មតំបន់សេដ្ឋកិច្ចទាំងអស់) គឺដោយមានភាពខ្លាំងក្លាជាង បើប្រៀបធៀបទៅនឹងការអភិវឌ្ឍទីផ្សារក្នុងតំបន់។ គឺមានតែវិស័យដែលធ្វើសមាហរណកម្មជាអាទិភាពទេដែលផ្តោតជាពិសេស ទៅលើការអនុវត្តនៅក្នុងតំបន់ និងការអភិវឌ្ឍទីផ្សារខាងក្នុង ("ធ្វើឡើងនៅក្នុងអាស៊ាន") ប៉ុន្តែគេនៅតែមើលឃើញថាតើគំនិតផ្តួចផ្តើមនេះទទួលបានជោគជ័យកម្រិតណានោះ។ វិស័យដែលធ្វើសមាហរណកម្មជាអាទិភាពត្រូវបានលើកឡើងនៅដើម ឆ្នាំ២០០៤ នៅក្នុង VAP ប៉ុន្តែរហូតមកដល់ពេលឥឡូវនេះ គ្មានការវិវឌ្ឍប្រកបដោយចីរភាពត្រូវបានរាយការណ៍ឡើយ។

វាត្រូវបានបង្ហាញថា ការធ្វើសេរីភាវូបណីយកម្មលើផ្នែកពាណិជ្ជកម្ម និងការវិនិយោគទុនអាចមានផលប៉ះពាល់អវិជ្ជមាន ដល់សេដ្ឋកិច្ច និងការងារក្នុងប្រទេស។ ការសិក្សាជាច្រើនក៏បានបង្ហាញនូវការសង្ស័យផងដែរ ទៅលើការបញ្ជាក់ថា ការធ្វើសេរីភាវូបណីយកម្មធ្វើឱ្យពាណិជ្ជកម្មមានការកើនឡើងដែលនាំឱ្យមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំងឡើង។ ការសិក្សានេះបង្ហាញថាការលូតលាស់ មិនដើរតាមការធ្វើសេរីភាវូបណីយកម្មដោយស្វ័យប្រវត្តិនោះទេ។ បទពិសោធន៍របស់អាស៊ីអាគ្នេយ៍នៅក្នុងវិបត្តិហិរញ្ញវត្ថុក៏គួរអាចធ្វើជាការក្រើនរំឭកចំពោះតំបន់នេះផងដែរ។ វិធានការណ៍សេរីភាវូបណីយកម្មជាពិសេស ផ្នែកដើមទុនដែលអាចបណ្តាលឱ្យមានការប្រែប្រួលក្នុងលំហូរដើមទុន និងមានឥទ្ធិពលលើសេដ្ឋកិច្ចពិតប្រាកដ។ ដូចគ្នានេះ វាគឺជាការបើកច្រកទំនិញ និងវិស័យសេវាកម្មទៅកាន់ការប្រកួតប្រជែងពីប្រទេសផ្សេងៗទៀត។ ស្រដៀងគ្នានេះ

ដែរ គម្រោងធំៗ ដូចជាបណ្ដាញថាមពលដែលតភ្ជាប់គ្នាទៅវិញទៅមក. ការជម្រុញការដាំរុក្ខជាតិ ចម្រាញ់យកប្រេង ឬ ការបញ្ចូលការធ្វើសម្បទានអជីវកម្មរ៉ែមានសក្ដានុពលក្នុង (ក) ការផ្លាស់ប្ដូរសហគមន៍ដែលទទួលបានគម្រោងនេះ (ខ) ការ បង្កគ្រោះថ្នាក់ សន្ដិសុខស្បៀងដោយការជម្រុញការសម្អាត ឬ ការផ្លាស់ប្ដូរដីកសិកម្មសម្រាប់ការប្រើប្រាស់ ក្នុងការធ្វើកសិកម្ម ឬ សម្រាប់គោលបំណងក្នុងការដាំដុះរុក្ខជាតិចម្រាញ់ប្រេង និង(គ) ការបំពុលប្រភពទឹក និងការបំផ្លិចបំផ្លាញបរិស្ថាន ។ ផែន ការរបស់ AEC មិនបានកត់សម្គាល់ចំពោះគ្រោះថ្នាក់ទាំងស្រុងនោះទេ ហើយនេះមិនបានផ្ដល់ផែនការច្បាស់លាស់ ដើម្បី បង្ហាញនូវផលប៉ះពាល់អវិជ្ជមាននៃការធ្វើសេរីភាវូបណីយកម្ម និងគម្រោងសមាហរណកម្មធំៗ ។

ផែនការរបស់ AEC មិនមានការពិភាក្សាទៅលើរបៀបរៀនសូត្រពីការលូតលាស់សេដ្ឋកិច្ចបទពិសោធន៍នៃការអភិវឌ្ឍ នៃប្រទេសឈានមុខនៃអាស៊ានថែមទៀត ។ ជាអាទិ៍ វាមិនបានពិភាក្សាពីរបៀបគាំទ្រការពារដែលផ្ដល់ដោយប្រទេសម៉ាឡេស៊ី ថៃ និងឥណ្ឌូណេស៊ី បានជួយអភិវឌ្ឍឧស្សាហកម្មរបស់ប្រទេសទាំងនោះ ឬ វិធីនៃការធ្វើវិនិយោគទុនដ៏ធំធេងរបស់ប្រទេស សិង្ហបុរីក្នុងផ្នែកសេវាកម្មសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធមានសារៈសំខាន់ក្នុងការអភិវឌ្ឍទីផ្សារក្នុងប្រទេសរបស់ខ្លួន ។ ផ្ទុយមកវិញ ផែនការនេះបាននិយាយពីការលុបបំបាត់ទាំងស្រុងនូវយន្ដការការពារទាំងនេះ (ឧទាហរណ៍ តម្រូវការការអនុវត្ត ការងារ និងបញ្ញត្តិរបស់ប្រទេស គឺជារបាំងមិនមែនពន្ធគយ) និងការទាក់ទាញវិស័យឯកជន ។ នៅពេលដែលមានការលើក ឡើងអំពីការការពារអ្នកប្រើប្រាស់ និងគោលនយោបាយប្រកួតប្រជែងយន្ដការនេះមិនទាន់បានលើកឡើងនៅឡើយទេ ។ តម្លាភាព និងការទទួលបានព័ត៌មាន និងការចូលរួមរបស់ប្រជាពលរដ្ឋក៏មិនត្រូវបានពិភាក្សាជាផ្នែកមួយនៃការគាំពារទាំងនេះ ផងដែរ ។

មានចំណុចសកម្មភាព និងការកំណត់ពេលវេលាជាក់ លាក់នៅពេលដែលគោលនយោបាយសេរីភាវូបណីយកម្មពិត ប្រាកដត្រូវដាក់បញ្ចូល ប៉ុន្ដែផែនការរបស់ AEC មានការខ្វះខាតលើការពិក្សាពីតម្រូវការ ដូច្នេះសមាជិកអាចធ្វើសមាហរណ កម្មតាមធម្មតា ។ ការផ្ដល់ហិរញ្ញវត្ថុគឺមានសារៈសំខាន់នៅក្នុងការទទួលបាននូវគម្រោងជាច្រើនដែលមានកត់ត្រានៅក្នុងផែន ការរបស់ AEC ប៉ុន្ដែមិនមានការ ពិភាក្សាឱ្យបានគ្រប់គ្រាន់នូវរបៀបដែល CLMV ជាអាទិ៍ អាចទទួលបានធនធាន ដូច្នេះ ពួកគេអាចចូលរួមនៅក្នុង គម្រោងនេះ ។ ផែនការលំអិតគ្រាន់តែនិយាយអំពី IAI និងមូលនិធិអភិវឌ្ឍអាស៊ានដែលទាំងពីរនេះ ត្រូវបាន កំណត់យន្ដការសម្រាប់ការផ្ដល់ហិរញ្ញវត្ថុដែលភាគច្រើន គ្របដណ្ដប់ទៅលើគម្រោងកសាងសមត្ថភាព និងជំនួយ បច្ចេកទេស ។ វាមិនបាននិយាយអំពីមធ្យោបាយដែលសមា ជិកដែលមានធនធានជាងគួរតែជួយ ឬ គម្រោងមូលនិធិសម្រាប់ សមាជិកដែលក្រជាង ។ គេដឹងជាទូទៅថា ស្ថប័ន ដែលមិនមែនជាសមាជិករបស់អាស៊ាន (ឧទាហរណ៍ ធនាគារប្រចាំតំបន់ ស្ថាប័នអន្ដរជាតិ និងភាគីអ្នកផ្ដល់ជំនួយទ្វេ ភាគី) ដែលបរិចាគចំនួនទឹកប្រាក់ច្រើននៅក្នុងមូលនិធិប្រចាំតំបន់ច្រើនជាង អាស៊ានខ្លួនឯង ។ នៅពេលដែលមានតម្រូវការជំនួយបន្ថែម ការបរិចាគពីខាងក្រៅចំពោះមូល និធិប្រចាំតំបន់ដែលមានវិសម មាត្រដ៏ធំ អាចនឹងមានឥទ្ធិពលហួសប្រមាណលើអាទិភាពក្នុងការអភិវឌ្ឍរបស់អាស៊ាន និងសមាជិកដែលក្រខ្សត់របស់ខ្លួន ។ គឺថា វាអាចធ្វើទៅបានដែលគម្រោងដែលបានអនុវត្តគឺជាគម្រោងដែលធ្វើតាមអាទិភាពរបស់ម្ចាស់ជំនួយ ។

ក្រៅពីបញ្ហាក្នុងការផ្ដល់ហិរញ្ញវត្ថុ មានបញ្ហាធំជាង នេះមួយចំនួនទៀតដែលបានលើកឡើងជាសំណួរថាតើ សាមគ្គីភាព នៅក្នុងតំបន់នឹងសម្រេចទៅបានដោយរបៀបណានៅក្នុង AEC ។ ផែនការលំអិតបានបញ្ជាក់យ៉ាងច្បាស់អំពីការធ្វើឱ្យច្បាប់ របស់ AEC មានភាពចុះសម្រុងគ្នាជាមួយនឹងច្បាប់ និងបទបញ្ញត្តិអន្ដរជាតិ ប៉ុន្ដែមិនមានការពិភាក្សាទៅលើចំណាប់អារម្មណ៍ របស់ប្រទេសផ្សេងៗគ្នា នឹងត្រូវបានរៀបចំ និងការពារនៅក្នុងខ្លឹមសាររបស់ច្បាប់អន្ដរជាតិ ។

គំនិតសហគមន៍សេដ្ឋកិច្ចរបស់អាស៊ានបានផ្តល់លទ្ធភាពដ៏គួរឱ្យភ្ញាក់ផ្អើលសម្រាប់ប្រជាជននៅក្នុងតំបន់។ ទីបំផុតសហគមន៍ពិភពលោកត្រូវបានដាក់បញ្ចូលនូវការធ្វើសហប្រតិបត្តិការ ហើយប្រជាពលរដ្ឋបានមករួបរួមគ្នាធ្វើការងារជាមួយគ្នា និងជួយគ្នាទៅវិញទៅមក។ គោលគំនិតផ្តោតលើមូលដ្ឋានទីផ្សារ និងផលិតកម្មតែមួយនេះអាចមានន័យថា ផលិតករអាស៊ានពង្រីកទំនាក់ទំនង និងការផ្លាស់ប្តូរគ្នាទៅវិញទៅមក ព្រមទាំងស្មារតីជម្រុញឱ្យបំពេញបន្ថែមគ្នាទៅវិញទៅមក។ ហើយវាក៏អាចមានន័យផងដែរថា ផលិតផលពិតប្រាកដនៅតាមតំបន់-ហើយអ្នកទាំងនោះដែលជាផលិតករមកពីប្រទេសជាសមាជិកផ្សេងៗគ្នាចូលរួមចំណែកនៅក្នុងការផលិតនោះ អាចត្រូវបានលើកកម្ពស់។

ទោះជាយ៉ាងណាក៏ដោយ ក្នុងន័យនេះ គម្រោងលំអិតរបស់ AEC គឺមិនមែនជាគម្រោងលំអិតសម្រាប់សហគមន៍ឡើយ។ ដើម្បីធ្វើឱ្យ AEC ចូលរួមពាក់ព័ន្ធ គឺគួរតែមានការរៀបចំឡើងវិញ ហើយបញ្ចូលប្រជាជនឱ្យបានកាន់តែច្រើននៅក្នុងការធ្វើផែនការនិងការអនុវត្ត។ ការជម្រុញ ដើម្បីភាពរីកចំរើននឹងក្លាយទៅជាអ្វីមួយដែលគេចង់បាន ប្រសិនបើការជម្រុញលើកទឹកចិត្តដែលធ្វើឡើងនោះឆ្ពោះ ទៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនសាមញ្ញ និងសហគមន៍ទាំងឡាយ។ សហគមន៍ពិតប្រាកដ គឺជាសហគមន៍ដែលប្រជាជនសាមញ្ញអោបក្រសោបថែរក្សា និងតំណាងឱ្យបំណងប្រាថ្នា ឆ្ពោះទៅបង្កើតសាមគ្គីភាព និងការសហការគ្នារបស់ពួកគេ។

## តើអ្វីទៅជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលអាស៊ាន កំពុងតែដាក់បញ្ចូល ហើយតើវានឹងជះឥទ្ធិពលដូចម្តេចដែរទៅលើកសិករ?

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន(AFTA)គឺជាយន្តការសេដ្ឋកិច្ចស្នូលមួយនៅក្នុងអាស៊ាន។ គម្រោងនេះ ត្រូវបានអនុវត្តតាមរយៈយន្តការអនុគ្រោះពន្ធគយដ៏មានប្រសិទ្ធភាព ជារួម (CEPT) ដែលកំណត់ថា រាល់ពន្ធគយទាំងអស់នឹងត្រូវលុបបំបាត់នៅត្រឹមឆ្នាំ២០១០ សម្រាប់សមាជិកអាស៊ាន ចំនួន៦ ហើយត្រឹមឆ្នាំ២០១៥ សម្រាប់ CLMV។ គ្រប់ផលិតផលសំខាន់ៗទាំងអស់នឹងត្រូវដាក់បញ្ចូលទៅក្នុងយន្តការនេះនៅត្រឹមឆ្នាំ ២០១៨។

ក្រៅពីពាណិជ្ជកម្មសេរីអាស៊ាន (AFTA) អាស៊ានបាន ចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) ចំនួន៦ ផ្សេង ទៀតធ្វើជាតំបន់មួយ។ កិច្ចព្រមព្រៀងទាំងនេះ រួមមាន :

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA)- កម្មវិធីប្រមូលផលលើកដំបូងពាក់ព័ន្ធ និងផ្លែឈើ និងបន្លែដែលត្រូវបានអនុវត្តរួចហើយ ជាមួយនឹងប្រទេសហ្វីលីពីន ប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ ហើយការចរចាជាមួយតំបន់ផ្សេងៗទៀតកំពុងឈានដល់ទីបញ្ចប់។
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA)-កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាលើកលែងតែប្រទេសថៃ មួយ
- ដៃគូពាណិជ្ជកម្មបើកទូលាយអាស៊ាន-ជប៉ុន (AJCEP)- ការចរចាត្រូវបានបញ្ចប់ទាំងស្រុង ហើយកិច្ចព្រមព្រៀងរំពឹងថានឹងត្រូវចុះហត្ថលេខា នៅដើមឆ្នាំ២០០៨
- ពាណិជ្ជកម្មតំបន់ និងតំបន់វិនិយោគអាស៊ាន-ឥណ្ឌា- ការចរចានានាពីទំនិញត្រូវបានរំពឹងថានឹងបញ្ចប់នៅ ខែឧសភា ឆ្នាំ២០០៨
- កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-អូស្រ្តាលី និងណូវែលហ្សេឡង់-ការចរចាកំពុងតែបន្ត

* កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន-សហភាពអឺរ៉ុប -សេចក្តីប្រកាសរួមត្រូវបានចុះហត្ថលេខារួចហើយ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ប៉ុន្តែការចរចាមិនទាន់ បាន ចាប់ផ្តើមនៅឡើយទេ
* តំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងកើត(EAFTA)-កំពុងស្ថិតនៅក្រោមការប្រឹក្សា និងសិក្សានៅឡើយ ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានខ្លួនឯងទទួល រ៉ាប់រងនូវចំណែកតូចល្មមនៃផ្នែកខាងក្នុងអាស៊ាននិងពាណិជ្ជកម្មអាស៊ានទាំងមូល ហើយវាស្ថិតនៅក្រោមការតាមឃ្លាំមើលថាតើនៅត្រឹមឆ្នាំ២០១៥ តំបន់ពាណិជ្ជកម្មសេរីនឹងជួយឱ្យកិច្ចព្រមព្រៀងនេះមានការរីចំរើនទៅមុខដែរឬអត់ ។ កិច្ចព្រមព្រៀងនានាជាមួយប្រទេសមួយចំនួនផ្សេងទៀតអាចនឹងផ្តួចផ្តើមឱ្យមានការគ្របដណ្តប់ទៅលើតែផលិតផលមួយផ្នែកតូចប៉ុណ្ណោះ ហើយមានអំឡុងពេលអនុវត្តរយៈពេលវែង ។ តែទោះជាយ៉ាងណាក៏ដោយ ទិសដៅជាទូទៅគឺឆ្ពោះទៅបើកចំហពាណិជ្ជកម្មឱ្យកាន់តែមានភាពរីកចំរើនទៅមុខជាមួយនឹងប្រទេសទាំងនេះ ។ បញ្ហា ចម្បងចំពោះកសិករនោះ គឺថាតើកិច្ចព្រមព្រៀងពាណិជ្ជ កម្មសេរីទាំងនេះនឹងជះឥទ្ធិពលអ្វីខ្លះទៅលើកសិកម្មក្នុងស្រុក ។ ឧទាហរណ៍ ការសិក្សាស្រាវជ្រាវដែលបានផ្តួចផ្តើមឡើងនៃកម្មវិធីប្រមូលផលជាលើកដំបូងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) បានបង្ហាញឱ្យឃើញនូវផលប៉ះពាល់មិនល្អដល់ប្រជាជនថៃ និងប្រជាជនឥណ្ឌូណេស៊ី ។

**តើយើងមានកង្វល់សំខាន់ៗអ្វីខ្លះពាក់ព័ន្ធនឹងកសិកម្មនៅ ក្នុងប្រទេសដែលជាសមាជិកអាស៊ាន?**

កម្មសិកម្មបន្តក្លាយជាវិស័យកាន់តែមានសារសំខាន់ និងជាវិស័យដ៏រសើបនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសសមាជិកអាស៊ានភាគច្រើនលើសលុប ។ លើកលែងតែប្រទេសសឹង្ហបូរី និងប្រទេសប្រ៊ុយណេចេញ ការចូលរួមវិភាគទាននៃវិស័យនេះទៅក្នុងទិន្នផលសេដ្ឋកិច្ចនាំចេញ គឺមានចាប់ពី ៧.៩% ដូចជាករណីនៅក្នុងប្រទេសម៉ាឡេស៊ី ឡើងរហូត ដល់ ៥០% ដូចជា នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមនិតឡាវ ជាដើម ។

ការចូលរួមចំណែកនៃវិស័យកសិកម្មទៅក្នុងការបង្កើតការងារសរុប គឺចាប់ពី ១៦% រហូតដល់ ៧៨% ។ កសិកម្មគឺនៅតែជាប្រភពដ៏សំខាន់សម្រាប់ជីវិតរស់នៅ និងការរកប្រាក់ចំណូលសម្រាប់ប្រជាជនទូទៅ ជាពិសេស ប្រជាជនរស់នៅតាមតំបន់ជនបទ ។

ថ្វីបើកសិកម្មនៅតែជាវិស័យដ៏សំខាន់មួយនៅក្នុងសេដ្ឋ កិច្ចអាស៊ានភាគច្រើនលើសលុបយ៉ាងណាក៏ដោយ ក៏យើងទាំងអស់គ្នាដែលជាកសិករ និងផលិតករប្រុស/ស្រីតូចតាច ហើយដែលមានចំនួនយ៉ាងច្រើនក្នុងចំណោមប្រជាជនទាំងអស់ គឺពឹងផ្អែកលើកសិកម្មនោះ គឺនៅតែមានជីវភាពក្រីក្រនៅឡើយ ។ នៅក្នុងអាស៊ាន ភាពក្រីក្រមានកម្រិតខ្ពស់បំផុត និងមានការរីករាលដាលយ៉ាងឆាប់រហ័សនៅក្នុងតំបន់ជនបទដែលកសិកម្មគឺជាប្រភពដ៏សំខាន់សម្រាប់ជីវភាពរស់នៅ ។

ភាពក្រីក្ររបស់យើងបង្កឡើងជាចម្បងដោយការផ្តល់ធនធានមិនមានសមភាពមិនមានលទ្ធភាពទទួលបានឱកាសសេដ្ឋកិច្ច និងការចូលរួមរបស់យើងមានកម្រិតតិចតួចនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចផ្សេងៗ ។

ការធ្វើសមាហរណកម្មកសិកម្មទៅក្នុងប្រទេសសមាជិកអាស៊ាននៅពេលថ្មីៗនេះមិនមានផលប្រយោជន៏ដល់កសិករប្រុស/ស្រីតូចតាចឡើយ ក៏ប៉ុន្តែការធ្វើពាណិជ្ជកម្ម កសិកម្មទ្រង់ទ្រាយធំ និងក្រុមហ៊ុនឆ្លងប្រទេសនានាកំពុងតែប្រមូលផលប្រយោជន៏ ។ ដោយចេះតែបន្តទៅមុខ និងដោយគ្មានការត្រួតពិនិត្យការធ្វើសមាហរណកម្មនេះនឹងបន្តបណ្តេញយើងចេញធ្វើឱ្យបាត់បង់របរចិញ្ចឹមជីវិតរបស់យើង និងធ្វើឱ្យបាត់បង់កេរដំណែលនៅតាមទីជនបទ រួមទាំងវប្បធម៌របស់សហគមន៏កសិកម្មនៅអាស៊ីអាគ្នេយ៏ផងដែរ ។ កសិករស្ត្រីទទួលនូវបន្ទុកធ្ងន់ធ្ងរពេលដែលពួកគាត់ធ្វើការងារកសិកម្មរហូតដល់ ៥០% ឬ លើសពី

នេះទៅលើ ស្ទើរគ្រប់ប្រភេទដំណាំទាំងអស់។ ដោយសារតែមានប្រាក់ចំណូលទាប ពួកគាត់នឹងមានថវិកាតិចតួចសម្រាប់ទិញស្បៀងអាហារ ព្យាបាលសុខភាព និងផ្តល់ការអប់រំដល់គ្រួសារទាំងមូល។

**តើមានការអំពាវនា និងសំណើសំខាន់ៗអ្វីខ្លះសម្រាប់ អាស៊ាន?**

គោលការណ៍ : ក្នុងនាមជាកសិករ និងផលិតករប្រុស/ ស្រីក្នុងទ្រង់ទ្រាយតូច សេចក្តីត្រូវការរបស់យើង គឺមានលក្ខណៈធម្មតា : យើងចង់បានមុខរបរចិញ្ចឹមជីវិតប្រកបដោយសន្តិសុខ និងមានភាពសមរម្យ ដូច្នេះជីវិតរស់នៅនឹងកាន់តែមានសុភមង្គល និងពោរពេញដោយសេចក្តីពេញចិត្ត។

គោលនយោបាយកសិកម្មរបស់អាស៊ាន គួរតែចូលរួម ចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីកាត់បន្ថយភាពក្រីក្រ ដោយចាត់ទុកថា កសិកម្ម គឺជានិយោជកដ៏សំខាន់របស់ប្រជាជនក្រីក្រភាគច្រើនរបស់ខ្លួន។ គេមិនគួរធ្វើឱ្យមានការបណ្តេញចេញ ឬ ធ្វើឱ្យកើនឡើងនូវភាពងាយរងគ្រោះដែលមានស្រាប់នៅក្នុងវិស័យនេះឡើយ។ ជាមួយគ្នានេះផងដែរ គោលនយោបាយទាំងនេះគួរតែយល់ថា កសិកម្មដើរតួយ៉ាងសំខាន់នៅក្នុងការឆ្លើយតបចំពោះសន្តិស្បៀងអាហារ និងតម្រូវការឱ្យមានគ្រប់គ្រាន់នូវស្បៀងអាហារចាំបាច់ជាក់ស្តែងរបស់ប្រទេសនីមួយៗ។

ដូច្នេះសមាហរណកម្មកសិកម្មត្រូវតែធ្វើឡើងក្នុងគរិយាបទមួយដែលលើកកម្ពស់ភាពរីកចំរើនដល់ប្រជាជនទាំងអស់ជាមួយនឹងជម្រើសដែលមានការអនុគ្រោះដល់ប្រជាជនក្រីក្រ និងអ្នកដែលទទួលបានផលប្រយោជន៍តិចតួច។ ហើយវាគួរតែមានសមភាព បើកទូលាយ មាននិរន្តរភាព ផ្អែកលើសិទ្ធិមនុស្ស និងយល់ដឹងពីយែនឌ័រព្រមទាំងឈានទៅផ្តល់អំណាចដល់ប្រជាជនក្រីក្រ។

គោលនយោបាយ : យើងស្នើសុំឱ្យអាស៊ានអភិវឌ្ឍនូវគោលនយោបាយយុទ្ធសាស្ត្រមួយសម្រាប់កសិកម្មដែលរួមបញ្ចូលពាណិជ្ជកម្ម និងការអភិវឌ្ឍ ហើយលើកកម្ពស់គោលនយោបាយដែលយើងបានស្នើឡើង។ គោលនយោយបាយយុទ្ធសាស្ត្រនេះអាចត្រូវបានអនុវត្តជាលើកដំបូងនៅថ្នាក់ជាតិ បន្ទាប់ពីធ្វើឱ្យមានស្ថេរភាព ហើយនិងត្រូវបានសម្របសម្រួលនៅតាមថ្នាក់តំបន់។ គោលនយោបាយនេះ គួរតែមានគោលការណ៍ និងលក្ខណៈពិសេសនានាដូចខាងក្រោម :

១. កសិករប្រុស/ស្រីតូចតាចត្រូវការជួយជ្រោមជ្រែងមួយចំនួនដំបូងគេ : ដីធ្លីដើម្បីរៀបចំ។ នៅក្នុង ប្រទេសឥណ្ឌូនេស៊ី ដីកសិកម្មយ៉ាងច្រើនស្ថិតនៅក្នុងផែនការគ្រប់គ្រងរបស់រដ្ឋ ឬ ម្ចាស់ចំការធំៗ។ ចំណែកឯនៅក្នុងប្រទេសហ្វីលីពីនវិញ ដីកសិកម្មសំខាន់ៗយ៉ាងច្រើន គឺស្ថិតនៅក្នុងកណ្តាប់ដៃម្ចាស់ដីដែលជាអ្នកមានឥទ្ធិពលនៅក្នុងអង្គនីតិប្រតិបត្តិអង្គនីតិបញ្ញត្តិ និងនៅក្នុងស្ថាប័នតុលាការនៅក្នុងជួររដ្ឋាភិបាល។ គោលនយោបាយកសិកម្មនេះ នឹងបង្កើតឱ្យមានលទ្ធភាព និងធ្វើការគ្រប់គ្រងធនធានដី ដែលជាកត្តាសំខាន់ដំបូងបង្អស់សម្រាប់ពាណិជ្ជកម្ម និងការអភិវឌ្ឍ។
២. ផ្តល់នូវសេវាផ្គត់ផ្គង់គ្រប់គ្រាន់ដល់កសិករខ្នាតតូច ដូចជា ធ្វើឱ្យពួកគាត់មានលទ្ធភាពប្រើប្រាស់ប្រាក់កម្ចី/ដើមទុន បច្ចេកវិទ្យា ការធានារ៉ាប់រងលើគ្រាប់ពូជ រួមទាំងការទ្រទ្រង់តម្លៃដោយផ្តោតគោលដៅជាសំខាន់ទៅលើកសិករស្ត្រី។
៣. ដាក់ទុនវិនិយោគលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឱ្យបានច្រើន ដើម្បីជួយទ្រទ្រង់ដល់អ្នកធ្វើកសិកម្មធុនតូច។
៤. ដឹកនាំការស្រាវជ្រាវ និងខិតខំប្រឹងប្រែងអភិវឌ្ឍឈានទៅលើកកម្ពស់គុណភាពផលិតផលក្នុងស្រុក។
៥. ធានាឱ្យមានគ្រប់គ្រាន់នូវដំណាំចាំបាច់សម្រាប់ប្រទេសដោយខ្លួនឯងនៅពេលដែលផលិតករត្រូវបានជួយក្នុងការផលិតស្បៀងអាហារឱ្យបានគ្រប់គ្រាន់ ហើយស្របទៅតាមបទដ្ឋានសុវត្ថិភាព និងបរិស្ថាន ហើយនៅពេលដែលរដ្ឋាភិបាល

ព្យាយាមធ្វើឱ្យមានតុល្យភាពរវាងផលិតកម្ម និងតម្រូវការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការផលដំណាំក្នុងស្រុកជាមុនសិន មុនពេលបំពេញតម្រូវការនៅក្រៅប្រទេសសម្រាប់លក់ប្តូរយករូបិយប័ណ្ណ

៦. ផ្តល់នូវសេរីភាវូបណីយកម្ម និងការការពារតាមកម្រិតក្នុងការឈានទៅការពារការងារ និងមុខរបរចិញ្ចឹមជីវិតរបស់ផលិតករខ្នាតតូច ដើម្បីសម្របទៅតាមលក្ខខណ្ឌជាក់លាក់ និងសេចក្តីត្រូវការរបស់ប្រទេសនីមួយៗដែលជាសមាជិក។

៧. ធ្វើទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងសស្រុក ហើយក៏ដូចជាផ្តោតទៅលើការធ្វើទំនាក់ទំនងរវាង ឧស្សាហកម្ម កសិកម្ម និងឧស្សាហកម្មផលិតម្ហូបអាហារផងដែរ។ ផលប្រយោជន៍របស់ផលិតករ និងអ្នកប្រើប្រាស់ផ្ទាល់ អាចរួមចូលគ្នាតាមរយៈការប្រើប្រាស់ពាណិជ្ជកម្ម និងការគ្រប់គ្រងតម្លៃដែលធានាបានថា គម្លាតតម្លៃរវាងផលិតផលនាំចូល និងផលិតផលប្រើប្រាស់ក្នុងស្រុកមិនមានទំហំធំឡើយ។

៨. ធ្វើការបញ្ជ្រាបកសិកម្មប្រកបដោយនិរន្តរភាពតាមរយៈការពង្រីកនិងការលើកកម្ពស់ផលិតកម្ម។ បង្កើតបទដ្ឋានសម្រាប់ផលិតកម្មប្រកបដោយនិរន្តរភាព និងសមស្រប និងសម្រាប់ផ្នែកទីផ្សារផងដែរ។ ដូច្នេះ កសិករ និងពាណិជ្ជករទាំងនោះនឹងត្រូវបានលើកទឹកចិត្តឱ្យផលិត និងលក់តែផលិតផលណាដែលបាន ផលិតក្នុងដំណើរការប្រកបដោយនិរន្តរភាព និងមានសុវត្ថិភាពដល់ការប្រើប្រាស់ប៉ុណ្ណោះ។ ការធ្វើបែបនេះ នឹងនឹងលើកទឹកចិត្ត ដើម្បីផលិត និងលក់សមស្របមានសុវត្ថិភាព និងចីរភាព ដើម្បីឱ្យទទួលបានផលចំណេញសមស្របណាមួយដល់ផលិតករខ្នាតតូច។

៩. បង្កើតយន្តការ ដើម្បីឱ្យមានការចូលរួមពីសំណាក់អង្គការផលិតករ/កសិករប្រុស/ស្រីធុនតូច និងអង្គការអភិវឌ្ឍសង្គមមិនមែនរដ្ឋាភិបាលក្នុងដំណើរការសេចក្តីសម្រេចរបស់អាស៊ាន ដូចជាក្រុមប្រឹក្សាកសិករអាស៊ាន (ASEAN Farmers' Council) ដែលក្រុមមន្ត្រីអាស៊ាន អាចធ្វើការប្រឹក្សាលើបញ្ហានានាដែលនាំឱ្យមានការប៉ះពាល់ដល់វិស័យផ្សេងៗរបស់ពួកគេ។ ដើម្បីឈានទៅធានាឱ្យបាននូវការចូលរួមប្រកបដោយគុណភាព ថ្នាក់គ្រប់គ្រង អាស៊ានគួរតែ :

- បើកចំហលក្ខខណ្ឌនានានៃការចរចាពាណិជ្ជកម្មឱ្យទាន់ពេលវេលាដើម្បីធ្វើការពិភាក្សាឱ្យបានពេញលេញ
- រៀបចំការពិភាក្សាជាសាធារណៈ ហើយធ្វើការប្រឹក្សា ជាពិសេស ជាមួយកសិករ និងអ្នកនេសាទទ្រង់ទ្រាយតូច រួមទាំងក្រុមសង្គមស៊ីវិលផងដែរ។
- បកស្រាយលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទៅជាពាក្យសំរាយ ហើយបកប្រែវាជាភាសាទៅតាមតំបន់នីមួយៗ
- ផ្តល់ការឧទ្ទេសនាមជាគំរូអំពីផលិតករប្រុស/ស្រីតូចតាចនៅក្នុងស្ថាប័នប្រឹក្សាពិគ្រោះយោបល់ និងធ្វើការសម្រេចចិត្តនេះ

## តើ AFA បានធ្វើអ្វីទាក់ទងនឹងអាស៊ាន ?

AFA ចាប់ផ្តើមចូលពាក់ព័ន្ធជាមួយអាស៊ាននៅក្នុងឆ្នាំ ២០០៥ នៅពេលដែលវាមានសហគ្រប់គ្រងជាមួយនឹងដៃគូជាយុទ្ធសាស្ត្ររបស់ខ្លួន គឺមាន DHRRA ដែលគឺជាការប្រជុំស្តីពី "អាស៊ាន និងកសិកម្ម" ចូលរួមដោយលោកបណ្ឌិត **អាមីម៉េត ម៉ាឃៀ** (Azmi Mat Makhir) ជាមន្ត្រីជាន់ខ្ពស់នៃលេខាធិការដ្ឋានអាស៊ាន។ នេះគឺជាការប្រជុំពិភាក្សាមួយក្នុងចំណោមកិច្ចប្រជុំនានានៅក្នុងសន្និសីទស្តីពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងអាស៊ានដែលរៀបចំឡើងដោយភ្នាក់ងារបណ្តាញក្នុងតំបន់ជាច្រើន ដូចជា វេទិកាអាស៊ី, SEACA, Forcus on the Global South និងវិទ្យាស្ថាន Intitute for Global Justice ។

នៅដើមឆ្នាំ២០០៦ អាស៊ានបានបង្កើតក្រុមមនុស្សល្បីឈ្មោះ (EPG) ដែលមានតួនាទីក្នុងការផ្តល់អនុសាសន៍ស្តីពីក្របខ័ណ្ឌធម្មនុញ្ញអាស៊ាន។ AFA បានធ្វើការដោយប្រើបណ្តាញធំមួយហៅថា សាមគ្គីភាពសម្រាប់ការតស៊ូមតិរបស់ប្រជាជនអាស៊ាន (SAPA) ដែលនៅពេលនោះបានធ្វើពាក្យដាក់ស្នើសុំការត្រួតពិនិត្យសម្រេចចំនួនបីទៅកាន់ EPG ដែលពាក្យស្នើសុំមួយសម្រាប់ផែនការស្នូលនីមួយៗ របស់អាស៊ាន (សន្តិសុខ, សេដ្ឋកិច្ច និងវប្បធម៌សង្គម)។ នៅខែធ្នូ ឆ្នាំ២០០៦ AFA បានរួមគ្នាជាមួយអាស៊ី DHRRA បានរៀបចំកិច្ចប្រជុំជាក្រុមមួយស្តីពី "សមាហរណកម្មតំបន់អាស៊ាន លើវិស័យកសិកម្មដែលចោទជាសំនួរថា: តើវាជាអ្វី តើវានឹងត្រូវអនុវត្តរបៀបណា" ។ កិច្ចប្រជុំជាក្រុមបានរៀបចំឡើងនៅក្នុងអំឡុងពេលនៃសន្និសីទរបស់សង្គមស៊ីវិលអាស៊ាន (ACSC2) នៅទីក្រុង សេប៊ូ (Cebu) ប្រទេសហ្វីលីពីន។

នៅឆ្នាំ២០០៧ AFA បានបង្កើនចំណងទាក់ទងជាមួយ អាស៊ានដោយបានរៀបចំការប្រឹក្សានៅក្នុងតំបន់ចំនួនពីរ លើក និងដោយបានចូលរួមនៅក្នុងសន្និសីទរបស់សង្គមស៊ីវិលចំនួនបីលើកមុនកិច្ចប្រជុំកំពូលរបស់ថ្នាក់ដឹកនាំអាស៊ាននៅក្នុងទីក្រុងសាំងហ្គាពួរ។ កិច្ចប្រឹក្សាមួយត្រូវបានប្រារព្ធឡើងនៅខែមីនា និងផ្តោតលើពង្រាងធម្មនុញ្ញ វុក្ខជាតិចម្រាញ់ប្រេង និង FTAs ទ្វេភាគី។ លទ្ធផលនៃការប្រឹក្សានេះត្រូវបានបញ្ជូនទៅអគ្គលេខាធិការរបស់អាស៊ាន គឺលោក **អុង កេងយ៉ុង** (Ong Keng Yong) និងមន្ត្រីជាន់ខ្ពស់ជាច្រើនទៀត។ នៅខែធ្នូ ការប្រឹក្សាមួយ ត្រូវបានរៀបចំឡើងនៅពេលនោះ គឺផ្តោតទៅលើការវិភាគទៅលើធម្មនុញ្ញរបស់អាស៊ានដែលបានចុះហត្ថលេខា និងផែនការលំអិតរបស់សហគមន៍សេដ្ឋកិច្ចដោយមានមន្ត្រីជាន់ខ្ពស់ពីររូបគឺ: បណ្ឌិត **សោមសាក់ ភីផូពីនយ៉ូ** (Somsak Pippopinyo) និង បណ្ឌិត **ធឺមសាក់ ឆាលឺផាឡានូផាប** (Termsak Chalermpalanupap)។ AFA ក៏បានចូលរួមផងដែរនៅ កិច្ចប្រជុំលើកទី៦ របស់ប្រជាជនអាស៊ានដែលរៀបចំឡើងដោយ ASEA-ISIS, និង ACSC នាឆ្នាំ២០០៧ ដែលរៀបចំឡើងដោយវិទ្យាស្ថានសឹង្ហបូរីសម្រាប់កិច្ចការអន្តរជាតិ និង ACSC+៣ រៀបចំឡើងដោយ SAPA។

## តើយើងអាចធ្វើអ្វីដើម្បីជម្រុញអាស៊ានឱ្យមានការពាក់ព័ន្ធពីបញ្ហានានា លើធម្មនុញ្ញអាស៊ាន AEC និងកសិកម្មជាទូទៅរបស់អាស៊ាន?

ចំពោះក្រុមកសិករ និងផលិតករដូចជាពួកយើងនៅ ក្នុង AEA យើងត្រូវការរៀបចំពង្រឹង និងសាមគ្គីរវាងពួកយើងទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីឱ្យយើងអាចមានសំឡេងខ្លាំងក្លាប្រសិទ្ធភាព និងឥទ្ធិពលនៅលើគោលនយោបាយក្នុងប្រទេស និងក្នុងតំបន់។ យើងមិនអាចប្រកួតប្រជែងរឿងបញ្ហាប្រាក់កាសនៃក្រុមហ៊ុនពាណិជ្ជកម្មធំៗបានទេ ប៉ុន្តែយើមានចំនួនពិតប្រាកដរបស់យើង។ យើងប្រកួតប្រជែង ហើយយើងប្រហែលជាមានប្រៀបជាងគេនៅក្នុងការតាំងចិត្ត និងការលះបង់ ប៉ុន្តែការការតាំងចិត្តរបស់យើង គឺឆ្ពោះទៅរកការធ្វើជំនួញប្រកបដោយយុត្តិធម៌ត្រឹមត្រូវ និងការតាំងចិត្តឆ្ពោះទៅរកការធ្វើកសិកម្មចម្រុះ និងមានសារៈសំខាន់សម្រាប់ការរស់នៅ។

រួមដៃគ្នាជាមួយក្រុមសង្គមស៊ីវិលដែលមានចមណាប់អរម្មណ៍ដូចគ្នា យើងអាចផ្លាស់ប្តូរព័ត៌មាន និងទស្សន និងជួយជម្រុញកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រជាជន។ តាមរយៈការសហការជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋភិបាល យើងអាចអនុវត្តគម្រោង និងកម្មវិធីស្តីពីផលិតកម្មដំណាំ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព រួមទាំងគម្រោងទីផ្សារ និងការធ្វើពាណិជ្ជកម្មប្រកបដោយប្រសិទ្ធិផល ប៉ុន្តែមានភាពត្រឹមត្រូវ និងយុត្តិធម៌។ តាមរយៈការធ្វើបែបនេះ យើងអាចកសាងសមត្ថភាពរបស់យើង ដើម្បីធ្វើការគ្រប់គ្រងដោយខ្លួនឯងបាន និងដើម្បីសហគ្រិនភាព។

ចំណុចមួយចំនួនខាងក្រោមនេះគឺជាកិច្ចការដ៏សំខាន់ដែលយើងអាចធ្វើបាន ដើម្បីបង្ហាញពីឥទ្ធិពលទៅលើវិធីសាស្ត្រដែលអាស៊ានធ្វើការអភិវឌ្ឍនូវតំបន់ភាវូបណីយកម្មនិយមរបស់ខ្លួន ៖

- ធ្វើការពិភាក្សាឱ្យបានហ្មត់ចត់ពីបញ្ហានានានៅក្នុងធម្មនុញ្ញអាស៊ានក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងគោលនយោបាយកសិកម្មរបស់ខ្លួនទៅដល់កសិករ និងផលិតករប្រុស/ស្រីតូចតាចឱ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន
- បង្ហាញឱ្យដឹងពីកង្វល់ផ្សេងៗរបស់យើងតាមរយៈការទាមទារ និងចូលរួមនៅក្នុងការពិគ្រោះពិភាក្សា ថ្នាក់តំបន់ និងថ្នាក់ជាតិស្ដីពីធម្មនុញ្ញរបស់អាស៊ាន និងផែនការលំអិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន
- ចូលរួមក្នុងការពិភាក្សាពីផ្នែកផ្សេងៗដែលមិន ទាន់បានបញ្ជាក់ឱ្យច្បាស់នៅក្នុងធម្មនុញ្ញអាស៊ាន ជាពិសេសផ្នែកដែលពាក់ព័ន្ធនឹងក្រុមសិទ្ធិមនុស្ស និងការកំណត់តួនាទី និងមុខងាររបស់សមាសភាពថ្មីដែលបានបង្កើតឡើង (ឧទាហរណ៍៖ គណៈកម្មការអ្នកតំណាងអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសហគមន៍)
- ជម្រុញឱ្យមានការបញ្ជាក់ និងកំណត់ពីទំហំសម្រាប់ការចូលរួមរបស់ប្រជាជននៅក្នុងអាស៊ាន រួមទាំងផ្ដល់ជាយន្តការផ្សេងៗដែលសមស្របសម្រាប់វិស័យរបស់យើង
- ជម្រុញឱ្យមានការពិភាក្សាពីគោលដៅទូលំ ទូលាយនៃសហគមន៍សេដ្ឋកិច្ចលើសពីសេរីភាវូបណីយកម្ម រួមទាំងចងក្រងជាអនុសាសន៍ជាក់ លាក់ផ្សេងៗទៀត
- ផ្ដល់អនុសាសន៍លើគោលការណ៍ជាក់លាក់ និងចំណុចសកម្មភាពសម្រាប់យន្តការការពារនៅក្នុងផែនការលំអិត AEC
- ធ្វើការណែនាំនូវគោលនយោបាយ និងគម្រោង ជាក់លាក់សម្រាប់ផ្នែកទាំងឡាយណាដែលមិនទាន់មានការបញ្ជាក់នៅក្នុងផែនការលំអិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ដូចជា ៖ ការការពារអ្នកប្រើប្រាស់, គោលនយោបាយប្រកួតប្រជែង, កម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍការសហការក្នុងវិស័យកសិកម្ម
- ចូលរួមក្នុងការអភិវឌ្ឍផែនការលំអិតស្ដីពីសន្តិសុខនយោបាយ និងសហគមន៍វប្បធម៌សង្គម។
- សិក្សាពីក្រុមកសិករតាមតំបន់ដទៃទៀតដែលធ្វើការជាមួយនឹងរដ្ឋាភិបាលនៅតាមតំបន់របស់គេ។
- ជាបន្តបន្ទាប់បង្កើត និងអនុវត្តរៀបចំឯកសារ ដោយផ្លាស់ប្ដូរគ្នាតាមរយៈពិសោធន៍កម្មដែលជាជំនួយនៃការអនុវត្ត និងការឆ្លើយតបយ៉ាងល្អដែលមានសក្ដានុពលនៃគោលគំនិតជោគជ័យដែលបានព្យាយាមនិងធ្វើការពិសោធន៍។
- ភ្ជាប់ទំនាក់ទំនងអាស៊ានក្នុងការបង្កើតនូវប័ណ្ណត្រួតពិនិត្យដែលនឹងវាស់វែងការអនុវត្តការងាររបស់រដ្ឋាភិបាលអាស៊ាននៅក្នុងតំបន់កសិពាណិជ្ជកម្ម ការទទួលបាន និងភាពជាម្ចាស់លើធនធានធម្មជាតិ កសិកម្មដែលប្រកបដោយនិរន្តភាព និងការចូលរួមរបស់កសិករ។

## សេចក្ដីសន្និដ្ឋាន

រូបសញ្ញាបច្ចុប្បន្នរបស់អាស៊ានមានគូស្រូវចំនួន១០ ហើយមានគោលបំណងចែងក្នុងឯកសារបង្កើតអាស៊ានក្នុងដោយផ្អែកលើការអភិវឌ្ឍ និងការបង្កើនទិន្នផលកសិកម្មនៅក្នុងតំបន់។

ក្នុងនាមជាកសិករប្រុស/ស្រីតូចតាចនៅតំបន់អាស៊ីអាគ្នេយ៍ បញ្ហាប្រឈមដែលធំបំផុតរបស់យើងសព្វថ្ងៃ គឺវិធីសាស្ត្រដើម្បីឆ្លើយតបទៅនឹងបញ្ហាជាច្រើនដែលកំពុងប្រឈមមុខជាមួយយើងនៅក្នុងកម្រិតដ៏ច្រើនដូចជា នៅតាមតាមកសិដ្ឋាន តាមសហគមន៍ ថ្នាក់ជាតិ ថ្នាក់តំបន់ និងក្នុងសកលលោកទាំងមូល។ ក្នុងនាមជាផលិតករផ្ទាល់ យើងដឹងអំពីអ្វីដែលយើងនិយាយ។ យើងផលិតអាហារដែលផ្គត់ផ្គង់ដល់សង្គមជាតិ ហើយយើងនឹងរក្សាផលិតភាពដី។ ក្នុងវិស័យមួយនេះ យើងស្ថិតនៅ

ក្រោមការគំរាម គំហែងជាច្រើន រួមមាន ការផ្លាស់ប្តូរដី និងការគ្រប់គ្រងកសិពាណិជ្ជកម្មធំៗ។ ការរក្សាអោយបាននូវប្រព័ន្ធកសិកម្មខ្នាតតូចជាកិច្ចការចំបងមួយក្នុងពិភពលោកនាពេលបច្ចុប្បន្នពេលដែលកសិកម្មខ្នាតធំក្លាយជាមានសារៈសំខាន់សម្រាប់ការរស់នៅ។ ការការពាររបស់យើងគឺស្ថិតនៅត្រង់សមត្ថភាពរបស់យើងចំពោះការដោះស្រាយបញ្ហាប្រឈមនានាក្នុងតំបន់ និងក្នុងប្រទេស។ យើងនឹងកាន់តែមានកម្លាំងខ្លាំងឡើងថែមទៀត ប្រសិនបើយើងអាចធ្វើការជាមួយកសិករទាំងអស់នៅក្នុងតំបន់ និងជម្រុញឆ្ពោះទៅកាន់ជំរើសដែលអាចជឿជាក់ និងស្ថិតស្ថេរបាន។

វាមានសារៈសំខាន់ណាស់ក្នុងការបង្ហាញថា យើង មិនមែនមានតែបំណងត្រឹមការរកបានទីផ្សារប៉ុណ្ណោះទេ ឧទាហរណ៍ដូចជា ការការពារដី និងបរិស្ថានដែលផ្តល់ អោយយើងនូវរបរចិញ្ចឹមជីវិត សាមគ្គីភាពជាមួយនឹងកសិករដទៃទៀត និងវិស័យផ្សេងទៀតរបស់សង្គម ការការពាររបៀបរបបរស់នៅរបស់កសិករ ។ល។ ការកើនឡើងអន្តរកម្មរវាងកសិករ និងកសិករក៏អាចធ្វើឡើងតាមរយៈការផ្លាស់ប្តូរព័ត៌មាន និងកម្មវិធីសាមញ្ញនានា (ឧទាហរណ៍ : ការធ្វើបញ្ជីគ្រាប់ពូជតាមតំបន់ដោយប្រជាជន ដើម្បីទប់ស្កាត់ការគ្របដណ្តប់ពីការធ្វើជំនួញគ្រាប់ពូជដោយកសិពាណិជ្ជកម្មខ្នាតធំ។ លទ្ធភាពដែលផលិតរួមគ្នាអាចធ្វើទៅបានលើផលិតផលឧបភោគបរិភោគសំខាន់ៗដែលអាចជំនះបានរាល់ដំណាក់កាលផលិតកម្មសំខាន់ៗ ចាប់ពីការដាំរហូតដល់ការប្រមូលផលរហូត ដល់ការកែច្នៃ និងការលក់ដូរ ។ល។)។ បំណងប្រាថ្នា និងគំនិតផ្តួចផ្តើមដែលមានភាពច្បាស់លាស់បែបនេះនឹងជាជំនួយក្នុងការបង្ហាញថា សហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់អាចធ្វើបានជាមួយនឹងប្រជាជនធម្មតានៅ តាមមជ្ឈមណ្ឌល។

## ឯកសារយោង


Charter of the Association of Southeast Asian Nations, Singapore, 20 November 2007. available online at: http://www.aseansec.org/AC.htm

ASEAN (2007). ASEAN Economic Community Blueprint. Available online at: http://www.13thaseansummit.sg/asean/index.php/web/documents/documents/asean_economic_blueprint

Chandra, A. and Chavez, J. (2008). "Civil Society Engagement with ASEAN: An Overview" in Chandra, A. and Chavez, J. (eds.), *Civil Society Reflections on South East Asian Regionalism: ASEAN@40*, pp. 21-36 (Quezon City: SEACA).

Chandra, A. and Chavez, J. (2008). "People-Centered Economic Solidarity: Beyond the Asean Economic Community Blueprint" in Chandra, A. and Chavez, J. (eds.), *Civil Society Reflections on South East Asian Regionalism: ASEAN@40*, pp. 91-106 (Quezon City: SEACA).

Chavez, J. and A. Chandra (2008). *Dilemmas of Competition and Community-Building: Developing Civil Society Response to Regional Trade and Economic Integration*, SEACA Occasional Papers, January.

SAPA – Solidarity for Asian Peoples' Advocacies Working Group on ASEAN (2007). Analysis of the ASEAN Charter. Available online at: http://ww.focusweb.org/analysis-of-the-asean-charter.html?Itemid=94

AFA. Reclaiming Spaces: Small Men and Women Famers Defining the Chalenge for ASEAN. A paper presented by Mr. Muhammad Nurddin during the ACSC;3 Confernece, Nov 3, 2007, Singapore.

Ofreneo, Rene E. (2006) "Neo-Liberalism and the Working People of Southeast Asia". in Focus on the Global South. /Revisiting Southeast Asian Regionalism, /pp 11-21 (Philippines: Focus on the Global South)

Credits:

Writer: Jenina Joy Chavez, Philippine Program Coordinator, Focus on the Global South
Editor: Ma. Estrella A. Penunia

Published by AFA
With support from Agriterra
(put logos of  AFA and Agriterra )

Rm 206, Partnership Center, 59 C. Salvador St., Loyola Heights, Quezon City , Philippines
www.asianfarmers.org;  afa@asianfarmers.org

Vol 3  No. 1. February 2008